# ចម្លើយចំពោះសេចក្ដីខ្វល់ខ្វាយ

នេះគឺជាសេចក្ដីអធិប្បាយដែលចែកចាយដោយលោកគ្រូគង្វាល Richard CALDWELL, Jr. នៅ ក្រុមជំនុំFounders Baptist

សាយ័ណាសួស្ដី។ ជាការល្អណាស់ដែលបានជួបបងប្អូននៅវេលាយប់នេះ។ សូមបងប្អូនបើកព្រះគម្ពីរ ១ពេត្រុស ៥ ហើយយើងអានពីខ៥ទៅ។ យើងនឹងអានរហូតដល់ខ១១។

*៥ ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឲ្យគ្រប់គ្នា*
*មានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់*
*ព្រះគុណដល់ពួករាបសាវិញ ៦ ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែ*
*របស់ព្រះចុះ ដើម្បីឲ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់ ៧ ហើយចូរផ្ទេរគ្រប់*
*ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹង*
*អ្នករាល់គ្នា។៨ ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់*
*គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេប*
*បាន ៩ ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែល*
*នៅក្នុងលោកីយ៍នេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ ១០ រីឯព្រះដ៏មានព្រះគុណសព្វគ្រប់*
*ដែលទ្រង់បានហៅយើងរាល់គ្នា មកក្នុងសិរីល្អនៃទ្រង់ ដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រី*
*ស្ទយេស៊ូវ នោះសូមទ្រង់មេត្តាប្រោសឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ទាំងចំរើនកំឡាំង*
*ហើយតាំងអ្នករាល់គ្នាឲ្យមាំមួនឡើង ក្នុងខណៈក្រោយដែលបានរងទុក្ខបន្តិច ១១ សូមឲ្យ*
*ទ្រង់បានសិរីល្អ នឹងព្រះចេស្តានៅអស់កល្បជានិច្ច ជារៀងរាបតទៅ អាម៉ែន។*

សូមអធិស្ឋានទាំងអស់គ្នា។

*ព្រះវរបិតាដែលគង់ស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណទ្រង់សំរាប់ឯកសិទ្ធិដែលទូលបង្គំមានក្នុងការបើកព្រះបន្ទូលហើយអធិប្បាយដល់រាស្ត្ររបស់ព្រះអង្គនៅវេលាយប់នេះ។ ទូលបង្គំសូមអរព្រះគុណទ្រង់សំរាប់ការនេះ ហើយទូលបង្គំទទួលស្គាល់ ឱព្រះអង្គអើយ ថាទូលបង្គំដឹងថា ទូលបង្គំមិនត្រឹមតែមិនស័ក្តសមចំពោះឯកសិទ្ធិនេះប៉ុណ្ណោះទេ ទូលបង្គំថែមទាំងគ្មានសមត្ថភាពធ្វើវាក្នុងរបៀបមួយដែលគាប់ព្រះហឫទ័យទៀតផង ហើយក៏មិនបានល្អសំរាប់រាស្ត្រទ្រង់ បើគ្មានអំណាចនិងសមត្ថភាពដែលទ្រង់ប្រទានមកតាមរយៈព្រះវិញ្ញាណរបស់ទ្រង់។ ដូច្នេះហើយ ព្រះអម្ចាស់អើយ ទូលបង្គំសូមឲ្យព្រះអង្គបានជួយទូលបង្គំ អធិប្បាយព្រះបន្ទូលនៅវេលាយប់នេះផង។ ព្រះអម្ចាស់*

*អើយ សូមប្រទានឲ្យទូលបង្គំមានគំនិតច្បាស់លាស់ ពាក្យសំដីងាយយល់ ហើយព្រះអម្ចាស់អើយ ទូលបង្គំអធិស្ឋានសូមព្រះវិញ្ញាណរបស់ទ្រង់ទទួលពាក្យសំដីរបស់ទូលបង្គំ នៅពេលដែលទូលបង្គំចែកចាយព្រះបន្ទូលរបស់ទ្រង់ ហើយព្រះអម្ចាស់អើយ សូមដាក់ព្រះបន្ទូលរបស់ទ្រង់ក្នុងចិត្តរបស់រាស្ត្រទ្រង់នៅក្នុងរបៀបមួយដែលមានលទ្ធផល នៅក្នុងរបៀបមួយដែលស្អាងចិត្ត នៅក្នុងរបៀបមួយដែលបង្ហាញឲ្យឃើញច្បាស់ពីទោសដែលមាន ព្រះអម្ចាស់អើយ ក្នុងរបៀបមួយដែលស្អាងឡើងហើយលើកទឹកចិត្ត។ ព្រះអម្ចាស់អើយ ទូលបង្គំសូមអធិស្ឋានសំរាប់បងប្អូនប្រុសស្រីនៅវេលាយប់នេះ។ ទូលបង្គំសូមអធិស្ឋាន ឱព្រះអម្ចាស់អើយ សូមឲ្យពួកគេបានទទួលបានព្រះពរពីព្រះបន្ទូលរបស់ទ្រង់។ ព្រះអម្ចាស់អើយ ទ្រង់ជ្រាបពីអ្វីដែលពួកគេត្រូវការ ហើយទូលបង្គំសូមទ្រង់បំពេញទូលបង្គំយើងខ្ញុំ មិនមែននូវអ្វីដែលទូលបង្គំគិតថាត្រូវការនោះទេ ប៉ុន្តែបំពេញនូវអ្វីដែលទ្រង់ជ្រាបថាទូលបង្គំយើងខ្ញុំត្រូវការនៅវេលាយប់នេះវិញ។ ទូលបង្គំយើងក៏អធិស្ឋានសំរាប់អស់អ្នកដែលកំពុងតែត្រូវការសេចក្ដីសង្គ្រោះនៅក្នុងចំណោមទូលបង្គំយើងខ្ញុំនៅវេលាល្ងាចនេះផងដែរ ព្រះអម្ចាស់អើយ។ សូមព្រះអង្គបានបង្ហាញព្រះគុណនិងព្រះចេស្តារបស់ទ្រង់ដោយនាំអ្នកណាម្នាក់តាមសំលេងរបស់ទូលបង្គំ ដើម្បីឲ្យបានមកឯសេចក្ដីជំនឿដ៏ពិតនៅក្នុងព្រះរាជបុត្រាយេស៊ូវរបស់ទ្រង់ផង ព្រះអង្គអើយ ទូលបង្គំយើងខ្ញុំដឹងថា ប្រសិនបើការនោះមិនកើតឡើង ព្រះបន្ទូលទ្រង់មិនដែលត្រឡប់ជាអសារឥតការឡើយ។ ដូច្នេះទូលបង្គំយើងខ្ញុំសូមដល់ទ្រង់ ព្រះអម្ចាស់អើយ បានដាំគ្រាប់ពូជនៃព្រះបន្ទូលរបស់ទ្រង់នៅក្នុងចិត្ត ឬបានស្រោចដល់គ្រាប់ដែលបានដុះហើយផងដែរ។ ហើយព្រះអម្ចាស់អើយ នៅពេលដែលសមស្ងួនពូជនោះនឹងបង្កើតផលផ្លែ។ ទូលបង្គំយើងខ្ញុំស្រឡាញ់ទ្រង់ ព្រះអង្គអើយ។ ទូលបង្គំយើងខ្ញុំសូមអរព្រះគុណទ្រង់សំរាប់សេចក្ដីស្រឡាញ់ដល់ទូលបង្គំយើងខ្ញុំ ហើយយើងអធិស្ឋានសំរាប់ការនេះនៅវេលាយប់នេះ នៅក្នុងព្រះនាមព្រះយេស៊ូវ អាម៉ែន។*

ការព្រួយបារម្ភ។ ការធ្លាក់ទឹកចិត្ត។ ភាពទុក្ខព្រួយ។ ការអស់សង្ឃឹម។ ការមិនពេញចិត្ត។ ការភ័យខ្លាច។ ពាក្យទាំងអស់នេះត្រូវបានឃើញ ដោយរបៀបណាមួយ ពាក្យទាំងអស់នេះមានទៅក្នុងព្រះបន្ទូលដែលយើងនឹងឃើញនៅក្នុងខ៧ ១ពេត្រុស ៥:៧ ថា រផ្ទេរគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា។ សេចក្ដីទុក្ខព្រួយ។ វាជាបញ្ហាដ៏ចម្បងមែនទេ? វាជាបញ្ហាដ៏ចម្បងមួយនៅក្នុងលោកិយនេះ។ នៅសប្តាហ៍ខ្ញុំបានអានវេបសៃពិសេសមួយ ខ្ញុំគិតថា ជាកន្លែងដែលផ្ដល់ប្រឹក្សា ជំនួយខ្លះសំរាប់អ្នកដែលកំពុងដោះស្រាយជាមួយសេចក្ដីទុក្ខព្រួយ។ ហើយនៅលើវេបសៃនេះ គេនិយាយថា ៨៣ភាគរយនៃអាមេរិកខាងជើងលេបថ្នាំសំរួលអារម្មណ៍ជារៀងរាល់ថ្ងៃ។ ចូរគិតអំពីការនោះ។ ស្ទើតែពាក់កណ្ដាលនៃចំនួនប្រជាជននៃប្រទេសអាមេរិក និងកាណាដាលេបថ្នាំដើម្បីសម្រួលអារម្មណ៍ ជារៀងរាល់ថ្ងៃ។

នៅក្នុងឆ្នាំ២០០២ Taxol and Zoloft—ថ្នាំទាំងពីរមុខនេះជាថ្នាំដែលប្រឆាំងនឹងអារម្មណ៍តានតឹង ដែលពេញនិយមជាងគេយ៉ាងហោចណាស់នៅក្នុងឆ្នាំ២០០២—ថ្នាំទាំងពីរមុខនេះជាប់លេខ៧និង លេខ៨នៅក្នុងឆ្នាំនោះក្នុងចំណោមថ្នាំរំងាប់អារម្មណ៍តានតឹងដែលនាំមុខគេទាំង១០មុខដែលចេញ ដោយវេជ្ជបណ្ឌិតនៅសហរដ្ឋអាមេរិក។ ដូច្នេះសូមគិតពីថ្នាំដែលចេញដោយវេជបញ្ជារទាំងអស់ នេះ។ ជាប់លេខ៧និងលេខ៨ក្នុងបញ្ជីថ្នាំរំងាប់អារម្មណ៍តានតឹងដែលនាំមុខគេទាំង១០។ ហើយថ្នាំ ទាំងពីរមុខនេះលក់បានលុយសរុបនៅឆ្នាំនោះគឺជិត៥ពាន់លានដុល្លារ។ ដូច្នេះការថប់បារម្ភមិន ត្រឹមតែជាបញ្ហាដ៏ធំមួយនោះទេ តែក៏ជាមុខជំនួញដ៏ធំមួយផងដែរ។ ហើយយើងដឹងពីបទគម្ពីរដែល ថា នេះមិនមែនគ្រាន់តែជាបញ្ហាសំរាប់មនុស្សបាត់បង់ប៉ុណ្ណោះទេ។ រាស្រ្តរបស់ព្រះក៏មានការថប់ ព្រួយដែលត្រូវដោះស្រាយដែរ មែនទេ?

ទំនុកដំកើង ៩៤: ១៩ ចែងថា៖

*"គ្រាដែលទូលបង្គំមានគំនិតសាន់វ៉ណ្តក្នុងចិត្តជាច្រើន នោះសេចក្តីកំសាន្តចិត្តនៃទ្រង់ក៏ជាទីរីករាយ ដល់ព្រលឹងទូលបង្គំវិញ"*។ ព្រះអម្ចាស់អើយ សេចក្តីកំសាន្តចិត្តនៃទ្រង់ជាទីរីករាយដល់ព្រលឹងទូល បង្គំ ប៉ុន្តែចូរសម្គាល់ថា គាត់បានទទួលស្គាល់ថា មានគ្រាដែលគាត់មានចិត្តថប់ព្រួយជាច្រើន។

ទំនុកដំកើង ១៣៩: ២៣ ចែងយ៉ាងដូច្នេះថា៖

*"ឱព្រះអង្គអើយ សូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលបង្គំផង សូមល្បងលឲ្យបានជ្រាបអស់ទាំង គំនិតនៃទូលបង្គំចុះ"*។

ហើយពាក្យហោព្រើរបកប្រែគំនិតដែលមានពាក្យមួយមានន័យត្រង់ៗថា គំនិតមិនស្ងប់ ឬថប់ព្រួយ។ តាមពិតទៅ ព្រះគម្ពីរ the New American Standard បកប្រែវាថា "ស្គាល់គំនិតថប់ព្រួយ"។

សុភាសិត 12:25 ចែងថា:

*"ការទុក្ខដែលគ្របសង្កត់ចិត្ត នោះធ្វើឲ្យរួញថយចុះ តែពាក្យល្អ១ម៉ាត់នឹងធ្វើឲ្យរីករាយឡើង"*។ ដូច្នេះយើងឃើញម្តងទៀតហើយថា ខទាំងអស់នេះទទួលស្គាល់ថា រាស្រ្តរបស់ព្រះ អ្នកច្រៀងទំនុកដំកើង អ្នកសរសេរ ឬសុភាសិត ហើយយើងរាល់គ្នាក្តីសុទ្ធតែដឹងសេចក្តីខ្វល់ខ្វាយនៅក្នុងចិត្តរបស់ យើង។ យើងដឹងវាជាសេចក្តីថប់ព្រួយអំពីអ្វីម្យ៉ាង។ យើងក៏ដឹងពីប្រវត្តិសាស្រ្តក្រុមជំនុំដែលបាវ បម្រើដ៏អស្ចារ្យខ្លះនៃដំណឹងល្អ មានការតស៊ូជាមួយនឹងការធ្លាក់ទឹកចិត្ត ហើយនិងសេចក្តីថប់ព្រួយ។

តើនរណាដែលសំខាន់ជាងគេនៅក្នុងចិត្តរបស់បងប្អូន? ប្រសិនបើបងប្អូនគិតពីអ្នកណាម្នាក់ដែល ល្បីល្បាញនៅក្នុងការបម្រើរបស់គាត់ ហើយជាគ្រូប្រកាសដំណឹងល្អម្នាក់ដែលត្រូវតស៊ូជាមួយនឹង ការធ្លាក់ទឹកចិត្ត តើអ្នកណានឹងមកក្នុងគំនិតរបស់អ្នក? លោក Charles Haddon Spurgeon មែន ទេ? នោះជាការតស៊ូដ៏ធំបំផុតជាមួយនឹងការថប់ព្រួយ។

ប៉ុន្តែសំនួរដែលខ្ញុំចង់សួរដើម្បីឲ្យយើងទាំងអស់គ្នាបានគិតនៅវេលាយប់នេះគឺយ៉ាងនេះ។ តើព្រះ ជាម្ចាស់មានចម្លើយមួយសំរាប់សេចក្តីថប់ព្រួយដែរឬទេ? តើព្រះជាម្ចាស់មានចម្លើយចំពោះចិត្ត

ដែលវិលវល់ដែរឬទេ? តើព្រះជាម្ចាស់មានចម្លើយចំពោះការខ្វល់ខ្វាយ ការភ័យខ្លាច ការធ្លាក់ទឹកចិត្ត និងការថប់ព្រួយដែរទេ? តើយើងត្រូវតែប្រើថ្នាំដើម្បីដោះស្រាយ ឬមានដំណោះស្រាយខាងបទគម្ពីរណាមួយសំរាប់វិញ្ញាណថប់ព្រួយនេះដែរឬទេ?
ដំណឹងល្អនៅវេលាយប់នេះគឺថា ព្រះជាម្ចាស់ពិតជាមានចម្លើយ ហើយចម្លើយនោះយើងបានរកឃើញនៅក្នុងព្រះគម្ពីរ ១ពេត្រុស ៥:៥-១១។
ចំនុចសំខាន់ពីរដែលខ្ញុំចង់ចែកចាយជាមួយបងប្អូននៅយប់នេះ។ ទីមួយ យើងនឹងនិយាយអំពីការវិភាគមួយនៃការថប់ព្រួយ។ យើងគ្រាន់តែចំណាយពេលដ៏ខ្លីដើម្បីទទួលស្គាល់អ្វីមួយដែលមកពីបទគម្ពីរ ហើយបន្ទាប់មក យើងនឹងមើលពីចម្លើយសំរាប់ការថប់ព្រួយ ហើយធ្វើការកត់សម្គាល់។ ខ្ញុំមិនបាននិយាយថា មានចម្លើយជាច្រើននោះទេ។ ខ្ញុំបាននិយាយថាចម្លើយ ពីព្រោះខ្ញុំគិតថា បងប្អូនអាចសរុបសេចក្ដីដោយខ្លួនឯង។ ប៉ុន្តែយើងនឹងពិនិត្យមើលថា ចម្លើយសំរាប់សេចក្ដីថប់បារម្ភនឹងត្រូវបានបង្ហាញឲ្យឃើញ។ វានឹងត្រូវបានបង្ហាញនៅក្នុងរបៀបផ្សេងៗជាច្រើន។ ដូច្នេះវាជាចម្លើយតែមួយទេ ប៉ុន្តែការបង្ហាញរបស់វា និងការប្រើប្រាស់វា គឺនឹងមានភាពផ្សេងៗគ្នាជាច្រើន។ ហើយយើងនឹងដើរនៅក្នុងចម្លើយនោះ យើងត្រូវតែមានបទពិសោធន៍នឹងការប្រើប្រាស់ក្នុងរបៀបជាច្រើនក្នុងជីវិតរបស់យើង។ យើងត្រូវតែប្រើចម្លើយនេះឲ្យបានល្អនៅគ្រប់ផ្នែកទាំងអស់។
ប៉ុន្តែ ដំបូង ចូរយើងគ្រាន់តែនិយាយថា វាជាអ្វីសិន។ ខ្ញុំបាននិយាយវារួចហើយ។ ប៉ុន្តែខ្ញុំគិតថា អ្វីដែលសំខាន់នោះ គឺយើងត្រូវទទួលស្គាល់អ្វីដែលយើងកំពុងតែនិយាយ នៅពេលយើងកំពុងនិយាយពីសេចក្ដីថប់ព្រួយ ពីព្រោះខ្ញុំគិតថា អ្វីដែលយើងធ្វើជាច្រើនដង គឺយើងមិនបានស្មោះត្រង់ពីអ្វីដែលយើងកំពុងតែដោះស្រាយ។ យើងកំពុងតែដោះស្រាយជាមួយសេចក្ដីថប់ព្រួយ យើងមិនចង់ទទួលស្គាល់ថាយើងជាមនុស្សបែបនោះ។ យើងដាក់ឈ្មោះឲ្យវា។ យើងហៅវាជាអ្វីម្យ៉ាងផ្សេងទៀតទៅវិញ។ អ្វីដែលគាត់និយាយនៅខ៧ថា ចូរផ្ទេរគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ តើវាជាអ្វីដែលយើងត្រូវផ្ទេរទៅលើទ្រង់? តើអ្វីទៅជាសេចក្ដីទុក្ខព្រួយ? ពិតមែនហើយ តើមានអ្នកណាម្នាក់នៅទីនេះធ្លាប់ខ្វល់ខ្វាយដែរឬទេ? នោះឯងជាសេចក្ដីទុក្ខព្រួយ។ សេចក្ដីខ្វល់ខ្វាយគឺជាទម្រង់មួយនៃសេចក្ដីទុក្ខព្រួយ។ អ្នកសំឡឹងមើលទៅអនាគត ហើយអ្នកគិតពីអ្វីអាចនឹងកើតឡើង ឬអ្វីដែលមិនអាចនឹងកើតឡើង ហើយចិត្តរបស់យើងក៏មានបញ្ហាចំពោះវា គឺការមិនស្កប់ចិត្ត។ ដូចជាអ្នកខ្លះអាចនឹងនិយាយថា អ្នកគ្រាន់តែមិន...។ ខ្ញុំគ្រាន់តែមិនសប្បាយចិត្ត។ ខ្ញុំគ្រាន់តែមិនពេញចិត្ត។ នោះឯងជាទម្រង់មួយនៃសេចក្ដីទុក្ខព្រួយ គឺការធ្លាក់ទឹកចិត្ត។ តើមានបងប្អូនណាមកទីនេះមានការធ្លាក់ទឹកចិត្តដែរឬទេ? ខ្ញុំអាចនឹងសួរបងប្អូនថា តើមានសេចក្ដីថប់ព្រួយឬទេ? ហើយបងប្អូនអាចនឹងនិយាយថា "ទេ ខ្ញុំគ្មានសេចក្ដីថប់ព្រួយទេ។ ខ្ញុំគ្រាន់តែធ្លាក់ទឹកចិត្តប៉ុណ្ណោះ។ ចិត្តរបស់ខ្ញុំគ្រាន់តែមិនសប្បាយប៉ុណ្ណោះ"។ នោះហើយជាទម្រង់មួយនៃសេចក្ដីទុក្ខព្រួយនោះ គឺការមិនសប្បាយចិត្ត ការភ័យខ្លាច។ តើបងប្អូននៅទីនេះមានសេចក្ដីភ័យខ្លាចដែរឬទេ? តាមពិតអំបោះរបស់គាត់រត់កាត់ចូលទៅក្នុងមនុស្សដែលមានសេចក្ដីដូចជាយើងបាននិយាយរួចហើយនេះ

មែនទេ? ខ្ញុំចង់និយាយថា ខ្ញុំកំពុងតែមានការព្រួយបារម្ភ។ ហើយនោះជាអ្វី? វាជាទម្រង់មួយនៃការភ័យខ្លាច។ ខ្ញុំធ្លាក់ទឹកចិត្តអំពីអ្វីម្យ៉ាង។ ជាច្រើនដង ការធ្លាក់ទឹកចិត្តរបស់យើងមានការទាក់ទងនឹងអ្វីដែលយើងមានការភ័យខ្លាច។ តើការនេះនឹងបញ្ចប់នៅត្រង់ណា? តើវាធ្វើដំណើរទៅណា? តើអ្វីជាផ្លូវបញ្ចប់ ឬអ្វីទៅជាចុងបញ្ចប់នៃផ្លូវនោះ? តើខ្ញុំនឹងជួបអ្វី ប្រសិនបើវានៅតែបន្តទៅតាមផ្លូវនោះទៀត? ហ្នឹងហើយជាទម្រង់មួយនៃសេចក្តីទុក្ខព្រួយ។

នេះជាការពិពណ៌នាមួយដ៏អស្ចារ្យតាមបទគម្ពីរអំពីសេចក្តីទុក្ខព្រួយ។ ចូរមើលព្រះគម្ពីរទំនុកដំកើង ជំពូក ៤២ ហើយមើលនៅខ៥។

*៥ ឱព្រលឹងអញអើយ ហេតុអ្វីបានជាត្រូវបង្អោនចុះ*
*ហើយមានសេចក្តីសោប់សល់នៅក្នុងខ្លួនដូច្នេះ*
*ចូរសង្ឃឹមដល់ព្រះចុះ ដ្បិតអញនឹងបានសរសើរ*
*ដល់ទ្រង់ទៀត*
*ដោយព្រោះព្រះភក្ត្រទ្រង់ដែលតែងតែជួយ។*
*៦ ឱព្រះនៃទូលបង្គំអើយ ព្រលឹងទូលបង្គំត្រូវបង្អោន*
*នៅក្នុងខ្លួន*
*ហេតុនោះបានជាទូលបង្គំនឹកចាំពីទ្រង់ នៅក្នុងស្រុក*
*ក្បែរទន្លេយ័រដាន់ ភ្នំហ៊ើម៉ូន និងភ្នំមីតសារ*
*៧ ទីជំរៅហៅរកទីជំរៅផងគ្នា ដោយសូរឈូឆរនៃរម្ហូរលេក*
*អស់ទាំងរលក នឹងរំកាញ់ទឹកនៃទ្រង់*
*បានហូរមកគ្របទូលបង្គំហើយ*
*៨ ប៉ុន្តែព្រះយេហូវ៉ានឹងចាត់សេចក្តីសប្បុរសទ្រង់មក*
*នៅវេលាថ្ងៃ*
*ហើយនៅវេលាយប់ បទចំរៀងនៃទ្រង់នឹង*
*នៅជាមួយនឹងទូលបង្គំផង*
*គឺជាសេចក្តីអធិស្ឋានដល់ព្រះនៃជីវិតទូលបង្គំ។*
*៩ ® ទូលបង្គំនឹងទូលដល់ព្រះដ៏ជាថ្មដានៃទូលបង្គំថា*
*ហេតុអ្វីបានជាទ្រង់ភ្លេចទូលបង្គំ*
*ហេតុអ្វីបានជាទូលបង្គំត្រូវដើរទាំងទុក្ខព្រួយ*
*ដោយព្រោះការសង្កត់សង្កិនរបស់ខ្មាំងសត្រូវដូច្នេះ*
*១០ ពួកខ្មាំងសត្រូវ គេចំអកឲ្យទូលបង្គំ ប្រៀបដូចជាដាវ*
*ចាក់ក្នុងឆ្អឹងទូលបង្គំ*

*ដោយគេសួរជានិច្ចថា តើព្រះឯងនៅឯណា*
*១១ ឱព្រលឹងអញអើយ ហេតុអ្វីបានជាឯងត្រូវបង្អោនចុះ*
*ហើយមានសេចក្តីរសាប់រសល់នៅក្នុងខ្លួនដូច្នេះ*
*ចូរសង្ឃឹមដល់ព្រះចុះ*
*ដ្បិតអញនឹងបានសរសើរដល់ទ្រង់ទៀត*
*ដែលទ្រង់ជាសេចក្តីជំនួយ ហើយជាព្រះនៃអញ។*

នេះជាទំនុកដំកើងមួយ តាមពិតទៅ នោះជាអ្វីដែលមនុស្សម្នាក់លើកទឹកចិត្តដល់ខ្លួនឯងដោយសេចក្តីពិត។ គាត់មានការរសាប់រសល់ដោយពួកខ្មាំងសត្រូវ។ គាត់មានចិត្តរសាប់រសល់ដោយព្រោះពួកអ្នកដែលនិយាយចំអកដល់សេចក្តីជំនឿរបស់គាត់។ ហើយជាលទ្ធផលនៃភាពជាខ្មាំងសត្រូវនេះ លទ្ធផលនៃការចំអកនេះ គឺធ្វើឲ្យចិត្តរបស់គាត់ព្រួយ។ ហេតុអ្វីបានជាព្រលឹងខ្ញុំត្រូវបង្អោនចុះ? ដូច្នេះបានជាមានអារម្មណ៍ទុក្ខសោក និងទុក្ខព្រួយនេះ។ ប៉ុន្តែគាត់ក៏បានពិពណ៌នាវាថាជាសេចក្តីរសាប់រសល់។ ហេតុអ្វីបានជាមានសេចក្តីរសាប់រសល់នៅក្នុងខ្លួនដូច្នេះ? គាត់និយាយអំពីការទុក្ខព្រួយ និងអំពីអារម្មណ៍ដែលប្រៀបដូចជាព្រះជាម្ចាស់បានបំភ្លេចគាត់ហើយអញ្ចឹង។ តើការនេះជាអ្វី? នេះគឺជាសេចក្តីទុក្ខព្រួយ។

ឥឡូវសូមមើលត្រឡប់ទៅកាន់១ពេត្រុស ជំពូក ៥។ សំនួរនោះគឺ៖ តើមានចម្លើយមួយតាមបទគម្ពីរដែរឬទេ? តើមានចម្លើយមួយនៅក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ចិត្តទុក្ខព្រួយដែរឬទេ? ចម្លើយគឺ**មាន** ហើយវាសាមញ្ញហើយមានន័យត្រង់ៗស្រួលយល់ផងដែរ។

បងប្អូននឹងនិយាយថា "ចម្លើយនោះជាអ្វីទៅ? តើចម្លើយសំរាប់ចិត្តទុក្ខព្រួយនោះជាអ្វីទៅ"។ អញ្ចឹងចូរយើងមើលម្តងទៀត នៅខ៥។ *ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឲ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ ។ ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឲ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់ ។ ហើយចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា។*

អ្វីដែលជាចម្លើយដែលបងប្អូនឃើញគឺចាប់ពីខ៥ដល់ខ៧។ វាផ្តោតទៅលើពាក្យនេះ៖ **ការបន្ទាបខ្លួន**។

*"...ចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នា."*

តើបងប្អូនយល់ថានោះគឺជាពាក្យដែលសំដែងពីអ្វីដែលគាត់បានដាស់តឿននៅដើមខ៦ទេ? *"ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ"*។ តើខ្ញុំបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះ ដោយរបៀបណា? ខ្ញុំបន្ទាបខ្លួនខ្ញុំដោយការផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយទៅ

លើទ្រង់។ នោះឯងជារបៀបដែលខ្ញុំបន្ទាបខ្លួន។ ដូច្នេះចម្លើយសំរាប់ចិត្តទុក្ខព្រួយគឺ **ការបន្ទាបខ្លួន**។ ឬក៏យើងអាចទាញប្រាស់មកវិញយ៉ាងដូច្នេះថា។ ហេតុអ្វីបានជាយើងមានចិត្តទុក្ខព្រួយ? អ្វីជាចម្លើយ? គឺ**អំនួត**។

ខ្ញុំសូមសួរបងប្អូនមុនពេលនឹងយើងបន្តទៅទៀតថា តើបងប្អូនមានបញ្ហាជាមួយនឹងសេចក្តីទុក្ខព្រួយដែរទេ? តើបងប្អូនមានបញ្ហាជាមួយនឹងសេចក្តីខ្វល់ខ្វាយដែរឬទេ? តើបងប្អូនមានបញ្ហាជាមួយនឹងការធ្លាក់ទឹកចិត្តដែរទេ? ខ្ញុំសូមសួរថា តើបងប្អូនគិតថា ឫសគល់នៃបញ្ហារបស់បងប្អូន គឺជាអំនួតដែរឬទេ? តើវាជាការទីមួយដែលមាននៅក្នុងគំនិតរបស់បងប្អូនដែរឬទេ? ប្រហែលជាមិនមែនទេ មែនទេ? ពីព្រោះភាគច្រើន ពេលមនុស្សម្នាក់កំពុងតែដោះស្រាយជាមួយការធ្លាក់ទឹកចិត្ត ការព្រួយចិត្ត ការអស់សង្ឃឹមរបស់គេ ជាធម្មតាតើគេគិតអំពីខ្លួនគេដោយរបៀបណា? ពួកគេគិតអំពីខ្លួនឯងក្នុងរបៀបបន្ទាបមួយ មែនទេ? ជាការពិតណាស់ តាមរបៀបពិនិត្យតាមដានពីបុព្វហេតុនៃផ្នែកចិត្តវិទ្យា មនុស្សម្នាក់អាចនឹងនិយាយថា ពួកគេនោះមានបញ្ហាដោយមានស្មារតីគិតពីខ្លួនឯងទាបពេក។ ដូច្នេះ អ្នកពិនិត្យនោះ នឹងនិយាយថា បញ្ហានោះមិនមកពីការអំនួតទេ បញ្ហារបស់គាត់គឺថា គាត់មិនបានគិតឲ្យខ្ពស់ពីខ្លួនគាត់ប៉ុណ្ណោះ។ ប៉ុន្តែមានគ្រូពេទ្យចិត្តវិទ្យាដ៏អស្ចារ្យម្នាក់។ គាត់គឺជាគ្រូពេទ្យចិត្តវិទ្យាតែម្នាក់គត់ដែលដឹងពីចិត្តរបស់មនុស្សយ៉ាងច្បាស់។ មែនទេ? គឺយេរេមា ១៧:៩។ *"ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន"*។

ហើយនៅខបន្ទាប់ បានប្រាប់យើងថា មានម្នាក់ដែលអាចស្គាល់បាន ហើយអ្នកនោះជានរណា? គឺជាព្រះជាម្ចាស់។ មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះ ដែលដឹងថាមានអ្វីកើតឡើងនៅក្នុងចិត្តរបស់បងប្អូននៅវេលាយប់នេះបាន ហើយព្រះដ៏មានគ្រប់អំណាចព្រះចេស្តា បានបញ្ចេញឲ្យមានសៀវភៅនេះឡើង បានប្រាប់យើងថា ចម្លើយសំរាប់ចិត្តទុក្ខព្រួយ គឺជាការបន្ទាបខ្លួន ហើយបងប្អូនត្រូវបន្ទាបខ្លួនដោយផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយទៅលើទ្រង់។ ការនេះអាចនឹងធ្វើឲ្យយើងភ្ញាក់ផ្អើល ដែលម្នាក់ដែលស្គាល់ពីចិត្តរបស់យើង បានប្រាប់យើងថា បញ្ហានៃវិញ្ញាណទុក្ខព្រួយគឺជាអំនួត។ តើការនោះអាចកើតឡើងដោយរបៀបណាបាន?

អញ្ចឹងចូរគិតអំពីការនោះ។ ប្រសិនបើបងប្អូនជាកូនរបស់ព្រះ អ្វីដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់បងប្អូនអំពីអ្វីក៏ដោយ តើមុខងារនៃអ្វីទាំងអស់នោះកំពុងតែដំណើរការនៅក្នុងជីវិតរបស់បងប្អូនឥឡូវនេះដែរឬទេ? តើអ្វីទៅដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់ដល់បងប្អូនអំពីឥរិយាបទនិងគំនិតរបស់ទ្រង់ចំពោះបងប្អូន? តើព្រះអម្ចាស់នោះស្រឡាញ់បងប្អូនដែរឬទេ? តើទ្រង់មានអំណាចគ្រប់គ្រងលើទាំងអស់ដែរឬទេ? តើមានអ្វីខ្លះដែលកំពុងតែកើតឡើងនៅក្នុងពិភពលោកនេះ នៅវេលាយប់នេះ ដែលទ្រង់មិនបានជ្រាបនោះ? ដូច្នេះ ខ្ញុំគិតថា ទ្រង់ពិតជាជ្រាបយ៉ាងច្បាស់ពីស្ថានភាពរបស់បងប្អូន។ តើបងប្អូនគិតអញ្ចឹងទេ? ពិតមែនហើយ។ តើមានអ្វីមួយនៅក្នុងពិភពលោកនៅវេលាយប់នេះ ដែលព្រះជាម្ចាស់មិនអាចធ្វើបាន? ខ្ញុំចង់និយាយថា ទ្រង់ក្តាប់ព្រះហស្ត

ទ្រង់ជាប់។ ទ្រង់មិនអាចជួយដល់បងប្អូនបាន។ តើមានអ្វីមួយយ៉ាងដូច្នេះឬ? តើអ្វីទៅជាចម្លើយឱបងប្អូនស្ងួនភ្ងាអើយ? តើមានអ្វីដែលពិបាកពេកសំរាប់ព្រះជាម្ចាស់ឬ? ដូច្នេះ ព្រះជាម្ចាស់របស់បងប្អូនមិនត្រឹមតែជ្រាបពីស្ថានភាពរបស់បងប្អូនយ៉ាងច្បាស់ប៉ុណ្ណោះទេ ទ្រង់ថែមទាំងកំពុងសោយរាជ្យលើបល្លង្គរបស់ទ្រង់នៅវេលាយប់នេះផងដែរ គឺទ្រង់កំពុងតែគ្រប់គ្រងគ្រប់ការទាំងអស់។ អាម៉ែន?

បងប្អូននិយាយថា "អញ្ចឹង ព្រះជាម្ចាស់ជ្រាបគ្រប់ការទាំងអស់ ហើយទ្រង់មានអំណាចលើទាំងអស់ ហើយគ្រប់គ្រងលើការទាំងអស់"។ អញ្ចឹងសូមយើងដើរមួយជំហានទៀត។ មិនចាំបាច់ទេដែលទ្រង់ត្រូវតែធ្វើឲ្យបងប្អូនមានសុវត្ថិភាពនោះទេ ប្រសិនបើទ្រង់មិនបានស្រឡាញ់បងប្អូន ប្រសិនបើទ្រង់មិនយកព្រះហឫទ័យទុកដាក់ដល់បងប្អូននោះ។ អញ្ចឹង ប្រសិនបើទ្រង់ពិតជាស្រឡាញ់ ប្រសិនបើទ្រង់ពិតជាយកព្រះហឫទ័យទុកដាក់ដល់បងប្អូន នោះបងប្អូនមានម្នាក់ដែលជ្រាបគ្រប់ការទាំងអស់ហើយគ្រប់គ្រងទាំងអស់ តែងតែទតមើលពីការព្រួយបារម្ភរបស់បងប្អូន។ ជាការពិតណាស់ ប្រសិនបើបងប្អូនជឿបទគម្ពីររ៉ូម ៨:២៨-៣០ យើងនឹងស្គាល់ពីការនេះ។ ទ្រង់តែងតែធ្វើការ កំពុងតែធ្វើឲ្យការគ្រប់ការទាំងអស់ធ្វើការរួមគ្នាដើម្បីជាសេចក្តីល្អសំរាប់អ្នកដែលស្រឡាញ់ទ្រង់ ហើយពួកអ្នកដែលបានហៅមកតាមបំណងព្រះហឫទ័យទ្រង់។ តើពិតទេ? មានន័យថា នៅពេលបងប្អូន នៅពេលខ្ញុំ ខ្លាច នៅពេលដែលយើងរាល់គ្នាព្រួយបារម្ភ នៅពេលដែលយើងត្រូវបានគេមើលងាយ តើយើងកំពុងតែនិយាយអ្វីទៅកាន់ព្រះជាម្ចាស់? ទូលបង្គំមិនជឿព្រះអង្គទេ។ ទូលបង្គំមិនជឿថាទ្រង់ជ្រាប ឬថាទ្រង់គ្រប់គ្រងការទាំងអស់ ឬក៏ថាទ្រង់យកព្រះហឫទ័យទុកដាក់នឹងខ្ញុំទេ។

ជាការពិតណាស់ ទោះជាយើងដឹងឬមិនដឹងក៏ដោយ តើបងប្អូនដឹងពីអ្វីដែលបងប្អូនកំពុងតែនិយាយទៅកាន់ព្រះជាម្ចាស់ដែរឬទេ? ទូលបង្គំទុកចិត្តខ្លួនឯងជាជាងទុកចិត្តដល់ទ្រង់។ ទូលបង្គំទុកចិត្តខ្លួនឯងក្នុងការថែរក្សាខ្លួនឯងជាជាងទុកចិត្តដល់ទ្រង់ក្នុងការថែរក្សាទូលបង្គំ។ ឥឡូវខ្ញុំចង់និយាយដល់បងប្អូននៅក្នុងរបៀបនោះដែរ។ ប្រសិនបើបងប្អូនណាម្នាក់ក្រោកឈរឡើងនៅទីនេះហើយនិយាយថា "អូរ ខ្ញុំមានសមត្ថភាពក្នុងការថែរក្សាខ្លួនឯងបានល្អជាងព្រះជាម្ចាស់"។ តើនោះមិនមែនជាអំនួតទេឬអី? ដូច្នេះនៅពេលយើងខ្វល់ខ្វាយ នៅពេលយើងពេញដោយសេចក្តីថប់ព្រួយ តើនោះជាសេចក្តីអំនួតឬទេ? វាពិតជាសេចក្តីអំនួតមែន។ មែនទេ? នោះជាមូលហេតុបានជាគាត់បានប្រាប់ ឲ្យយើងបន្ទាបខ្លួនដោយការផ្ទេរគ្រប់ទាំងសេចក្តីខ្វល់ខ្វាយរបស់យើងទៅព្រះជាម្ចាស់។

ទាល់តែយើងធ្វើអញ្ចឹង ទាល់តែយើងឈប់គិតថាយើងអាចដោះស្រាយបានល្អជាងព្រះជាម្ចាស់ ទាល់តែយើងឈប់គិតថា ទ្រង់ពិតជាមិនជ្រាបឬទ្រង់មិនគ្រប់គ្រងការទាំងអស់ ឬទ្រង់មិនខ្វល់ចំពោះយើងរាល់គ្នា ទាល់តែគំនិតនិងចិត្តរបស់យើងផ្លាស់ប្រែពីការនេះ ហើយបោះបង់ចោលសេចក្តីអំនួតរបស់យើង។ តាមពិតទៅយើងបង្ខាំងខ្លួនឯងពីជំនួយរបស់ព្រះជាម្ចាស់។

បងប្អូននិយាយថា "តើបានគំនិតនេះពីណាមក?"
ចូរមើលនៅខ៥។

*ឲ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ ៦ ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឲ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់ ៧ ហើយចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា។*

ដូច្នេះចម្លើយចំពោះសេចក្តីខ្វល់ខ្វាយគឺសាមញ្ញណាស់គឺ **ការបន្ទាបខ្លួន**។ បញ្ហាដែលមានពោរពេញនៅក្នុងចិត្តរបស់យើងគឺ **សេចក្តីអំនួត**។ តើការបន្ទាបខ្លួននេះមានលក្ខណៈដូចម្តេច? ខ្ញុំបានប្រាប់ដល់បងប្អូនហើយ។ ចម្លើយគឺតែមួយទេ តែការប្រើប្រាស់ជាប្រយោជន៍គឺមានច្រើន។ តើការដើរនៅក្នុងសេចក្តីបន្ទាបខ្លួនមានលក្ខណៈយ៉ាងដូចម្តេច? នេះគឺជាការល្អសំរាប់យើងធ្វើ ពីព្រោះជូនកាលអ្វីដែលយើងធ្វើយើងស្មានថា យើងពិតជាកំពុងដើរនៅក្នុងសេចក្តីបន្ទាបខ្លួន ប៉ុន្តែបន្ទាប់ពីយើងក្រមើលពីការប្រើប្រាស់ជាប្រយោជន៍នៃសេចក្តីនេះ ប្រហែលជាព្រះជាម្ចាស់នឹងបើកបង្ហាញដល់យើងថា មានផ្នែកនានានៅក្នុងជីវិតរបស់យើង ដែលយើងតែកំពុងដើរនៅក្នុងសេចក្តីអំនួត ហើយការនោះអាចនឹងរកឃើញពីមូលហេតុដែលចិត្តរបស់យើងមានពោរពេញដោយបញ្ហា ពីព្រោះមានផ្នែកខ្លះយើងមិនទាន់បានបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់នៅឡើយ។

ដូច្នេះតើការបន្ទាបនេះមានលក្ខណៈយ៉ាងដូចម្តេច? មុនដំបូងគឺ កន្លែងណាដែលមានការបន្ទាបខ្លួនកន្លែងនោះមានការចុះចូលចំពោះអំណាច។ នៅដើមខ៦ "ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន..."។ វានាំយើងទៅខ៥ម្តងទៀត មែនទេ? អ្វីមួយដែលបានចែងនៅខមុនតភ្ជាប់ទៅនឹងការពិភាក្សានេះបានផ្តល់មកយើងនូវរបៀបដោះស្រាយចំពោះសេចក្តីខ្វល់ខ្វាយ។ នៅក្នុងជំពូក៥ ខ១ ដល់ខ៤ កំពុងតែផ្តល់ឲ្យយើងនូវការណែនាំដ៏ច្បាស់លាស់មួយចំពោះពួកចាស់ទុំ ជារបៀបដែលពួកគាត់មានទំនួលខុសត្រូវនៅក្នុងពួកជំនុំ។ បន្ទាប់មកនៅខ៥ ជាព្រះបន្ទូលនិយាយមកកាន់ពួកជំនុំ ហើយនិងពួកអ្នកដែលនៅក្នុងពួកជំនុំថា "*ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ*"។

ហេតុអ្វីបានជាព្រះបន្ទូលនោះនិយាយមកកាន់ពួកក្មេង? ពិតមែនហើយ ជាទូទៅ ពួកចាស់ទុំកំពុងតែក្លាយជាមនុស្សចាស់ជាងមនុស្សជាច្រើននៅក្នុងពួកជំនុំ ប៉ុន្តែយើងក៏ដឹងដែរថាពួកក្មេងៗមានការតស៊ូជាមួយនឹងអំណាច។ វាមិនពិតទូទៅនោះទេ ប៉ុន្តែវាពាក្យទូទៅមួយដែលពិតដែលថា ក្មេងៗនៅក្នុងករណីជាច្រើន មិនទ្រាំនឹងមនុស្សចាស់ទុំទេ ហើយដូច្នេះក្មេងៗ ជាពិសេស ត្រូវបានលើកទឹកចិត្តដើម្បីឲ្យបានចុះចូលចំពោះមនុស្សចាស់ទុំ។ ហើយនោះឯងជាការបង្ហាញឲ្យឃើញពីការបន្ទាបខ្លួន គឺជាការចុះចូលចំពោះមនុស្សចាស់ទុំ ដើម្បីឲ្យដឹងថាអំណាចរបស់មនុស្ស នៅខ៦ គឺជា **ព្រះហស្តដ៏ពូកែរបស់ព្រះ**។

ព្រះគម្ពីររ៉ូម ជំពូក១៣ ប្រាប់យើងថា គ្រប់អំណាច ព្រះជាម្ចាស់បានតាំងឡើង។ ដូច្នេះកន្លែងណាដែលមានការបន្ទាបខ្លួន កន្លែងនោះមានការទទួលស្គាល់មួយថា នោះជាកន្លែងដែលព្រះជាម្ចាស់បានតាំងអំណាចមនុស្សឡើង កន្លែងណាមានព្រះហស្តនៃព្រះ ហើយចិត្តបន្ទាបនឹងនិយាយថា "ខ្ញុំឃើញពីសេចក្តីត្រូវការក្នុងការចុះចូលចំពោះអំណាច ហើយខ្ញុំចង់ចុះចូលចំពោះអំណាច"។ ប៉ុន្តែចិត្តអំនួតវិញនិយាយថា "ខ្ញុំមិនត្រូវការរដ្ឋអំណាច ហើយខ្ញុំក៏មិនចុះចូលចំពោះអំណាចដែរ"។ អ្នកនឹងសួរថា "តើការនោះអាចដោះស្រាយចំពោះសេចក្តីខ្វល់ខ្វាយបានដោយរបៀបណា?"

មែនហើយ សូមឈប់សិន ហើយគិតអំពីរឿងនេះ។ ជាញឹកញាប់ តើអ្វីធ្វើឲ្យមនុស្សមានបញ្ហានៅក្នុងលោកិយនេះ? នោះគឺពាក់ព័ន្ធនឹងទំនាក់ទំនងរបស់ពួកគេ គឺអំពីមនុស្សម្នាក់ដែលមានអំណាចលើពួកគេ។ ក្មេងៗមានបញ្ហាដោយឪពុកម្តាយរបស់ពួកគេ ប្រពន្ធមានបញ្ហាដោយសារប្តីរបស់ពួកគេ បុគ្គលិកធ្វើការមានបញ្ហាដោយសារថៅហ្វាយរបស់ពួកគេ ជាដើម។ ហើយខ្ញុំសូមសួរសំនួរមួយដល់បងប្អូននៅយប់នេះថា តើបងប្អូនជឿថា ព្រះដ៏គ្រប់គ្រងលើសទាំងអស់ដែលគេត្រូវទុកចិត្ត ហើយជឿ ហើយទ្រង់មានបន្ទូលមកយើងរាល់គ្នា បានតាំងរចនាសម្ព័ន្ធរដ្ឋអំណាច ហើយទ្រង់ធ្វើការតាមរយៈរចនាសម្ព័ន្ធរដ្ឋអំណាចទាំងនោះដែរឬទេ?

នោះ ជាការពិតណាស់ សូម្បីតែអ្នកមានរដ្ឋអំណាចអយុត្តិធម៌ក៏ដោយ ក៏អ្នកនៅតែជាមនុស្សដែលចុះចូលឲ្យអស់ពីលទ្ធភាពដែលយើងអាចធ្វើទៅបានផងដែរ។ មែនទេ?

ដូចជាយើងមិនត្រូវឈប់ស្តាប់បង្គាប់អំណាចដ៏លើសទាំងអស់នៅក្នុងជីវិតរបស់យើង គឺជាព្រះជាម្ចាស់យ៉ាងដូច្នេះដែរ។ យើងត្រូវចុះចូលចំពោះអំណាចនោះ ពីព្រោះព្រះជាម្ចាស់បានតាំងវាឡើងមក។ ហើយដោយរបៀបណាមួយ ទ្រង់កំពុងតែធ្វើការតាមរយៈអំណាចនោះ។

នៅយប់នេះ តើមានមនុស្សប៉ុន្មាននាក់ចង់ឲ្យបាត់សេចក្តីខ្វល់ខ្វាយ ប្រសិនបើពួកគេជឿថា ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់ពួកគេ តាមរយៈមនុស្សម្នាក់ដែលមានអំណាចនិងឋានៈលើពួកគេនោះ? តើសេចក្តីខ្វល់ខ្វាយរបស់យើងប៉ុន្មាននឹងបាត់ទៅ ប្រសិនបើយើងទុកចិត្តដល់ព្រះជាម្ចាស់ជាមួយនឹងទំនាក់ទំនងនោះ ហើយនិយាយថា "ព្រះអម្ចាស់អើយ ទ្រង់បានតាំងអំណាចនេះឡើង សំរាប់ហេតុផលមួយ ហើយទោះបីជាមានពេលខ្លះវាមិនមែនជាទីពេញចិត្តដល់ទូលបង្គំក៏ដោយ ឬប្រហែលជាវាមានការលំបាកសំរាប់ខ្ញុំ តើព្រះអង្គជ្រាបទេ? ព្រះអង្គកំពុងតែធ្វើការនៅក្នុងអំណាចនេះ ហើយព្រះហឫទ័យទ្រង់កំពុងតែត្រូវបានសំរេចនៅក្នុងជីវិតរបស់ទូលបង្គំ ហើយទ្រង់បានត្រាស់ហៅទូលបង្គំឲ្យបង្ហាញពីសេចក្តីជំនឿដល់ទ្រង់ ដោយរបៀបដែលទូលបង្គំមានទំនាក់ទំនងជាមួយមនុស្សនេះដែលគាត់មានអំណាចលើទូលបង្គំ"។

ការបន្ទាបខ្លួននៅក្នុងពួកជំនុំមួយ បង្ហាញឲ្យឃើញពីការចុះចូលចំពោះពួកចាស់ទុំ។ ប៉ុន្តែត្រូវចងចាំថា នោះមិនមែនជាកន្លែងដែលសេចក្តីបន្ទាបខ្លួនឈប់ឡើយ។ សេចក្តីបន្ទាបខ្លួនមិនត្រឹមតែបង្ហាញដោយការចុះចូលចំពោះរដ្ឋអំណាចប៉ុណ្ណោះទេ តែសេចក្តីបន្ទាបខ្លួនត្រូវបង្ហាញដោយទស្សនៈត្រឹម

ត្រូវអំពីរដ្ឋអំណាច ឬក៏យើងអាចនិយាយថាជាការប្រើប្រាស់ត្រឹមត្រូវនៃរដ្ឋអំណាចផងដែរ។ តើបងប្អូនគិតថា មនុស្សនៅក្នុងរដ្ឋអំណាចធ្លាប់មានសេចក្តីខ្វល់ខ្វាយដែរឬទេ? មានតែមនុស្សនៅក្រោមរដ្ឋអំណាចប៉ុណ្ណោះដែលមានសេចក្តីខ្វល់ខ្វាយ ឬក៏មនុស្សនៅក្នុងរដ្ឋអំណាចមានសេចក្តីខ្វល់ខ្វាយផងដែរ?
សូមឲ្យខ្ញុំបានសួរដល់បងប្អូនតាមរបៀបនេះវិញថា តើអាចទៅរួចឬទេ ដែលមានមនុស្សកោតខ្លាចដល់ព្រះធ្វើការនៅក្នុងជួររដ្ឋអំណាច ដែលទ្រង់បានត្រាស់ហៅដើម្បីឲ្យដឹកនាំមនុស្សមួយក្រុមដែលមិនកោតខ្លាចដល់ព្រះ នោះ? ចុះអំពីលោកម៉ូសេ? នៅពេលគាត់នៅរស់ ព្រះគម្ពីរចែងថា គាត់ជាមនុស្សដែលបន្ទាបខ្លួនបំផុតនៅលើផែនដីនេះ។ តើនោះមិនមែនជាការប្រកាសដ៏អស្ចារ្យពីព្រះជាម្ចាស់ទេឬអី? គ្មានអ្នកណាម្នាក់បន្ទាបខ្លួនជាងលោកម៉ូសេទេ។

ឥឡូវនេះ តើគាត់ធ្លាប់ត្រូវបានចោទប្រកាន់ពីការមិនបានបន្ទាបខ្លួនដែរឬទេ? ចុះចំណែកការមិនចុះសំរុងជាមួយនឹងពួកបះបោរនោះយ៉ាងណាដែរ? តើអ្នកណាឲ្យអ្នកធ្វើជាមេគ្រប់គ្រងលើយើងរាល់គ្នា? អ្នកគិតពីខ្លួនឯងច្រើនពេក។ អ្នកដំកើងខ្លួនឯងក្នុងចំណោមបណ្តាជន។ មនុស្សដែលបន្ទាបខ្លួនបំផុតនៅលើផែនដីនេះត្រូវបានគេចោទថា មានអំនួតទៅវិញ។ សូមស្តាប់! នេះគឺជាសេចក្តីល្បួងសំរាប់អស់អ្នកដែលមានអំណាច គឺជាការរំលោភបំពានដោយប្រើអំណាចខ្លួនក្នុងផ្លូវខុស។ អ្នកកំពុងតែព្យាយាមដឹកនាំមនុស្សមួយក្រុមដែលរឹងចចេស ជាមនុស្សដែលប្រកាន់ខ្លួន ជាមនុស្សដែលមិនចេះដើរតាម។ ដូច្នេះសេចក្តីល្បួងនោះគឺជាការដែលមិនប្រើអំណាចតាមរបៀបមួយដែលកោតខ្លាចដល់ព្រះ ហើយទុកចិត្តព្រះអម្ចាស់ថាទ្រង់នឹងធ្វើអ្វីមួយដែលមានតែទ្រង់ប៉ុណ្ណោះដែលអាចធ្វើបាន ហើយទុកឲ្យទ្រង់សម្រេចលទ្ធផល សូម្បីតែពួកគេមិនបានធ្វើតាមក៏ដោយ។ ចូរអ្នកធ្វើអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យធ្វើ។ នេះឯងគឺជាការដែលយើងត្រូវធ្វើ។ ប៉ុន្តែសេចក្តីល្បួងគឺថា ទុកឲ្យខ្ញុំអនុវត្តអំណាចរបស់ខ្ញុំនៅក្នុងរបៀបមួយដែលខ្ញុំជឿថាត្រូវ។ ទេ! ខ្ញុំធ្វើវាក្នុងរបៀបមួយដែលមិនត្រឹមត្រូវហើយ។ ប្រសិនអ្នកឆ្ងល់ថាខ្ញុំបានរបៀបនេះមកពីណា សូមមើលទៅខបន្ទាប់មកទៀត។ បន្ទាប់ពីនិយាយថា ពួកក្មេងៗត្រូវចុះចូលចំពោះពួកចាស់ទុំ សាវក ប៉ុលក៏បាននិយាយថា *"ត្រូវឲ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ"*។
ដូច្នេះ ប្រសិនបើបងប្អូនកំពុងតែទាស់នឹងរដ្ឋអំណាចនោះ នៅយប់នេះបងប្អូនត្រូវតែពាក់សំលៀកបំពាក់នៃសេចក្តីបន្ទាបខ្លួន ទោះជាបងប្អូនមានទំនួលខុសត្រូវក្នុងការដឹកនាំក៏ដោយ ក៏បងប្អូនមានទំនួលខុសត្រូវក្នុងការដឹកនាំដោយមានចិត្តបន្ទាប។ បងប្អូនមិនអាចរំលោភបំពានដោយប្រើអំណាចបានទេ។ តាមពិតទៅ សូមមើលទៅបញ្ជីមួយនៅខ២ខាងលើ។ *"ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ ទាំងគ្រប់គ្រងដោយស្ម័គ្រពីចិត្ត មិនមែនដោយបង្ខំទេ ក៏មិនមែនដោយចង់បានកំរៃដែរ គឺដោយគាប់ចិត្តវិញ មិនមែនបែបដូចជាមានអំណាចលើរបស់ទ្រព្យទេ*

*គឺដើម្បីឲ្យបានធ្វើជាគំរូដល់ហ្វូងចៀមវិញប៉ុណ្ណោះ"។* មានសេចក្តីខ្វល់ខ្វាយជាច្រើនចេញពីជីវិតនៃមនុស្សដែលមានអំណាច នៅពេលដែលពួកគេនិយាយថា "ព្រះអម្ចាស់អើយ ទ្រង់បានតាំងទូលបង្គំឡើងឲ្យដឹកនាំមនុស្សទាំងនេះ ហើយទោះជាពួកគេមិនធ្វើតាមទូលបង្គំក៏ដោយ ទូកបង្គំនៅតែទទួលខុសត្រូវក្នុងការសរសើរដំកើងទ្រង់នៅក្នុងអ្វីដែលទូលបង្គំដឹកនាំពួកគេ។ ហើយព្រះអម្ចាស់អើយ ប្រសិនបើទូលបង្គំបានធ្វើអស់ពីសមត្ថភាពហើយ នោះគឺជាអ្វីគ្រប់យ៉ាងដែលទូលបង្គំអាចធ្វើហើយ"។ ដូច្នេះការចុះចូលចូលចំពោះអ្នកមានអំណាចគ្រប់គ្រង គឺជាការបង្ហាញនៃការបន្ទាបខ្លួន។ ទស្សនៈត្រឹមត្រូវនិងការប្រើប្រាស់ត្រឹមត្រូវចំពោះអំណាច គឺជាការបង្ហាញនៃការបន្ទាបខ្លួន។ មានរបៀបទីបី ដែលយើងអាចមើលឃើញការនេះសំដែងចេញមកនៅក្នុងខទាំងនេះ គឺជាការទទួលយកនូវបំណងព្រះហឫទ័យរបស់ព្រះ។ តើការបន្ទាបមានលក្ខណៈយ៉ាងដូចម្តេច? គឺជាការទទួលយកនូវការថែរក្សារបស់ព្រះជាម្ចាស់។ ចូរមើលនៅខ៦។ ចែងថា *"ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឲ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់"*។ ព្រះហស្តដ៏ពូកែរបស់ព្រះ បានបង្ហាញនៅក្នុងទំនាក់ទំនងទាំងនេះ យើងបាននិយាយរួចហើយ ប៉ុន្តែព្រះហស្តដ៏ពូកែរបស់ព្រះធ្វើការលើសពីទំនាក់ទំនងទាំងនោះទៀត។ ខ្ញុំគិតថា អ្វីដែលសាវក ប៉ុលមាននៅក្នុងគំនិតគាត់ជាពិសេសនោះ គឺការរងទុក្ខដែលមនុស្សទាំងអស់នេះមាននៅក្នុងលោកិយពីព្រោះគាត់បាននិយាយបន្តនៅទៀតនៅក្នុងខ៩ថា *"ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុងលោកីយ៍នេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ"។ រីឯព្រះដ៏មានព្រះគុណសព្វគ្រប់ ដែលទ្រង់បានហៅយើងរាល់គ្នា មកក្នុងសិរីល្អនៃទ្រង់ ដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ នោះសូមទ្រង់មេត្តាប្រោសឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ទាំងចំរើនកំឡាំង ហើយតាំងអ្នករាល់គ្នាឲ្យមាំមួនឡើង ក្នុងខណៈក្រោយដែលបានរងទុក្ខបន្តិច"*។

តើពួកគេកំពុងធ្វើអ្វី? ពួកគេកំពុងរងទុក្ខ។ ហើយជាលទ្ធផលក្នុងការរងទុក្ខរបស់ពួកគេ តើពួកគេត្រូវបានល្បួងឲ្យធ្វើអ្វី? ឲ្យមានពេញទៅដោយសេចក្តីខ្វល់ខ្វាយដូចជាអ្នកសរសេរព្រះគម្ពីរទំនុកដំកើងជំពូក៤២ កំពុងតែប្រឈមមុខនឹងខ្មាំងសត្រូវ ហើយជាលទ្ធផល ចិត្តរបស់គាត់ត្រូវបានបង្អោនចុះ។ សាវក ប៉ុលនិយាយថា *"ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ"*។ ព្រះហស្តគ្រប់គ្រងនៃព្រះ។ តើបងប្អូនជឿថា ព្រះជាម្ចាស់មានអំណាចគ្រប់គ្រងទាំងអស់ដែរឬទេ? តើបងប្អូនជឿថា ស្ថានភាពបច្ចុប្បន្នរបស់បងប្អូនបង្ហាញពីការថែរក្សារបស់ព្រះដែរឬទេ? មានន័យថា ព្រះជាម្ចាស់បានដាក់យើងនៅក្នុងត្រង់កន្លែងដែលយើងកំពុងតែនៅនេះ។ តើបងប្អូននឹងបន្ទាបខ្លួននៅទីនោះ ឬក៏បងប្អូនខំព្យាយាមថែរក្សាខ្លួនឯង គឺជាការដែលបងប្អូនប្រយុទ្ធគ្រប់ទិសទីដើម្បីរត់គេចចេញពីស្ថានភាពបច្ចុប្បន្នរបស់បងប្អូន? តើការបន្ទាបខ្លួនមានលក្ខណៈដូចម្តេច? ព្រះអម្ចាស់អើយ ទូលបង្គំទុកចិត្តទ្រង់ថា កន្លែងដែលទូលបង្គំកំពុងស្ថិតនៅពេលឥឡូវនេះ មិនមែន

កើតឡើងដោយចៃដន្យទេ។ អ្វីដែលទូលបង្គំកំពុងតែដោះស្រាយនៅក្នុងជីវិតនេះ យប់នេះ មិនមែនកើតឡើងដោយចៃដន្យទេ។ ទូលបង្គំនឹងទុកចិត្តទ្រង់នៅទីនេះព្រះអង្គអើយ។
មាននោះមិនមានន័យថា បងប្អូនមិនអាចខំព្យាយាមដើម្បីធ្វើឲ្យស្ថានភាពបានប្រសើរឡើងបានឡើយ ប្រសិនព្រះអម្ចាស់មិនអនុញ្ញាតិ? ពិតមែនហើយ បងប្អូនអាច។ ប៉ុន្តែបញ្ហាពិតគឺមិនមែនជាស្ថានភាពរបស់បងប្អូនឡើយ។ បញ្ហាពិតនោះគឺថា តើបងប្អូនទុកចិត្តព្រះអម្ចាស់ដែរឬទេ? ប្រសិនបើបងប្អូនមិនអាចផ្លាស់ប្តូរស្ថានភាពរបស់បងប្អូនបាន តើបងប្អូននឹងអស់សង្ឃឹមឬយ៉ាងណា? ឬក៏បងប្អូននឹងមានសេចក្តីអំណរ? បញ្ហាពិតមិនមែនជាការផ្លាស់ប្តូរនៃស្ថានភាពនោះទេ។ បញ្ហាពិតគឺជាការផ្លាស់ប្តូររបស់បងប្អូនវិញ។ ការទទួលយកនូវបំណងព្រះហរទ័យរបស់ព្រះ ការទទួលយកនូវការថែរក្សារបស់ព្រះ ដែលជាការបន្ទាបខ្លួនវិញ។
លោកនយ៉ូសែប បានឈរនៅចំពោះបងៗដែលបានលក់គាត់ឲ្យធ្វើជាទាសករ ហើយនៅចុងបញ្ចប់គាត់បានជាប់គុគ ហើយឥឡូវគាត់នៅទីនេះ គឺជាអ្នកធំទីពីរនៅក្នុងប្រទេសអេស៊ីព ហើយបងៗរបស់គាត់ឈរនៅចំពោះគាត់ មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះល្បិចកលរបស់ពួកគេ ពីព្រោះគាត់មានអំណាចអាចនឹងធ្វើទុក្ខទោសដល់ពួកគេបាន ប៉ុន្តែលោក យ៉ូសែប មិនមានសេចក្តីជូរល្វីងអ្វីសោះ មែនទេ? ហេតុអ្វីបានជាមនុស្សនោះមិនមានកំហឹងជាមួយនឹងពួកអ្នកដែលគាត់ចង់ឃើញពួកគេទទួលទណ្ឌកម្មសំរាប់អ្វីដែលពួកគេបានប្រព្រឹត្តិ? តើបងប្អូនឮពីគំនិតរបស់លោក យ៉ូសែបទេ? អ្នកធ្វើការនេះសំរាប់បំណងអាក្រក់ ប៉ុន្តែមានបំណងឲ្យការនេះបានជាសេចក្តីល្អវិញ។ អ្វីដែលជាការបង្ហាញទី៩នៃការបន្ទាបខ្លួន សូមមើលទៅ៥៧។ បងប្អូនបន្ទាបខ្លួនដោយផ្ទេរសេចក្តីខ្វល់ខ្វាយដល់ព្រះជាម្ចាស់។ ចូរដាក់សេចក្តីខ្វល់ខ្វាយរបស់អ្នកលើទ្រង់។ ពាក្យជាក់លាក់នោះត្រូវបានបកប្រែថា ការផ្ទេរ ដែលត្រូវបានប្រើនៅក្នុងព្រះគម្ពីរលូកា ១៩:៣៥ផងដែរ ហើយបាននិយាយពីការនេះ។ "រួចគេដឹកវាទៅ ថ្វាយព្រះយេស៊ូវ ក៏ក្រាលអាវគេលើខ្នង ហើយថ្វាយទ្រង់គង់" ។ ដូច្នេះពួកគេបានបោះអាវរបស់ពួកគេ ទៅលើខ្នងលា ពាក្យនោះនៅទីនេះ ដូចជាបោះក្រណាត់មួយផ្ទាំងទៅលើអ្វីម្យ៉ាង។ នេះគឺជាការផ្ទេរមួយ។ វាប្រៀបដូចជាដកយកសេចក្តីខ្វាល់ខ្វាយរបស់បងប្អូនចោលនៅវេលាយប់នេះដែរ ហើយបងប្អូនដាក់សេចក្តីខ្វល់ខ្វាយនោះមួយដុំ ហើយបោះទៅលើព្រះអម្ចាស់។ ហើយចូរសម្គាល់ថា នេះគឺជាការផ្ទេរទាំងស្រុង មែនទេ? ការគ្រាន់តែបោះសេចក្តីខ្វល់ខ្វាយខ្លះលើទ្រង់។ តើបទគម្ពីរបានចែងយ៉ាងដូច្នេះដែរឬទេ? គឺជាសេចក្តីខ្វល់ខ្វាយទាំងឡាយណាដែលបងប្អូនគិតថាទ្រង់អាចដោះស្រាយបាន។ ទេ! តើបទគម្ពីរបានចែងយ៉ាងដូចម្តេចវិញ? បោះចោលអ្វី? ទាំងអស់ ហើយនៅក្នុងបទគម្ពីរជាភាសាក្រិកមានពាក្យមួយដែលមានន័យថា ទាំងអស់។ សេចក្តីថប់បារម្ភទាំងអស់ សេចក្តីខ្វល់ខ្វាយទាំងអស់ សេចក្តីទុក្ខព្រួយទាំងអស់ គ្រប់ទាំងសេចក្តីដែលបងប្អូនភ័យខ្លាចនៅវេលាយប់នេះ គ្រប់ទាំងសេចក្តីដែលធ្វើឲ្យចិត្តរបស់បងប្អូនបានបង្អោនចុះ។ បងប្អូនត្រូវចងដាក់វាមួយដុំ ហើយត្រូវតែមានការផ្ទេរទាំងស្រុងមួយ។ នោះគឺជាការបន្ទាបខ្លួន។ ខ្ញុំនឹងបោះបញ្ហាសេចក្តីទាំងអស់នេះទៅព្រះអម្ចាស់ មានន័យថា ខ្ញុំនឹងថ្វាយគ្រប់

សេចក្ដីទាំងនោះដល់ទ្រង់។ ខ្ញុំនឹងទុកសេចក្ដីទាំងនេះក្នុងសេចក្ដីខ្វល់ខ្វាយរបស់ទ្រង់ ដោយដឹងថា នោះជាការដែលទ្រង់ឲ្យខ្ញុំធ្វើ។ នោះឯងជាសេចក្ដីបន្ទាបខ្លួន។

ចុះការនោះជាសេចក្ដីបន្ទាបខ្លួនដោយរបៀបណាទៅ? តើការបោះសេចក្ដីខ្វល់ខ្វាយរបស់បងប្អូនលើព្រះអម្ចាស់ ជារបៀបដែលបងប្អូនបន្ទាបខ្លួនដោយរបៀបណាទៅ? ពីព្រោះ ប្រសិនបើបងប្អូនមិនធ្វើការនេះនៅវេលាយប់នេះទេ ប្រសិនបើបងប្អូនមិនប្រមូលអស់ទាំងសេចក្ដីខ្វល់ខ្វាយទាំងនេះ ហើយបោះលើទ្រង់ទេ នោះចូរគិតពីអ្វីដែលបងប្អូនកំពុងតែនិយាយចុះ។ តាមពិតទៅ បងប្អូនកំពុងតែគ្រប់គ្រងសេចក្ដីទាំងអស់នេះដោយខ្លួនឯងហើយ។ មិនបាច់ថ្វាយសេចក្ដីទាំងអស់នេះដល់ព្រះជាម្ចាស់ទេ ពីព្រោះបងប្អូនកំពុងតែគ្រប់គ្រងសេចក្ដីទាំងអស់នេះហើយ។

តើបងប្អូនភ្ញាក់ដឹងខ្លួនឡើង ឱបងប្អូនជាទីស្រឡាញ់អើយ តើសេចក្ដីខិតខំរបស់យើងបានធ្វើអ្វីខ្លះសំរាប់យើង? ចូរភ្ញាក់ពីការយល់សប្តិឡើង។ យើងយល់សប្តិ។ យើងស្រមៃថា យើងមានវិធានការក្នុងការគ្រប់គ្រងជីវិតរបស់យើង ហើយព្រះជាម្ចាស់អនុញ្ញាតិឲ្យសេចក្ដីផ្សេងៗមកក្នុងជីវិតយើងដើម្បីដាស់យើង ហើយជួយយើងឲ្យបានភ្ញាក់ដឹងខ្លួនថា យើងមិនអាចគ្រប់គ្រងអ្វីបានទាំងអស់។ តើអ្វីខ្លះដែលបងប្អូនគិតថា បងប្អូនគ្រប់គ្រងបាន?

បងប្អូននិយយថា "អើ ខ្ញុំគ្រប់គ្រងការជាច្រើន។ ខ្ញុំបានដាក់ម៉ោងរោទិ៍នៅព្រឹកមិញ ហើយខ្ញុំបានភ្ញាក់ឡើងរួចទៅធ្វើការ ហើយខ្ញុំបានធ្វើនេះ ខ្ញុំបានធ្វើនោះ។ នេះហើយជាអ្វីដែលខ្ញុំសម្រេចបាន ហើយនិងអ្វីៗផ្សេងជាច្រើនទៀតដែរ"។

ហើយចូរស្តាប់!

ប្រសិនបើព្រះជាម្ចាស់មិនបានប្រោសប្រទានឲ្យមានជីវិត ខ្យល់ដង្ហើម និងចង្វាក់បេះដូងដល់បងប្អូនទេ បងប្អូនមិនអាចនឹងសម្រេចបានកិច្ចការទាំងអស់នេះបានឡើយ។ ប្រសិនបើទ្រង់មិនបានប្រទានសមត្ថភាពឲ្យចេះគិត នោះបងប្អូនមិនអាចធ្វើអ្វីបានទាំងអស់ ហើយប្រសិនបើបងប្អូនគិតថា បងប្អូនមិនបានពឹងលើព្រះសោះ នោះចូរចងចាំពីស្តេចនេបូក្នេសារ ដែលគាត់បានចេញទៅក្រៅ ហើយបានអបអរនូវអ្វីដែលគាត់សម្រេចបាននៅក្នុងនគររបស់គាត់ ហើយនៅក្នុងរំពេចនោះ ព្រះជាម្ចាស់បានធ្វើឲ្យមនុស្សនោះបានត្រឡប់ជារស់នៅដូចជាសត្វធាតុវិញ។ ហើយគាត់បានងើបឡើង ហើយសំអាតខ្លួនបានតែដរាបណាព្រះជាម្ចាស់បានប្រទានឲ្យមានគំនិតដឹងខុសត្រូវប៉ុណ្ណោះ។ បងប្អូនមិនបានគ្រប់គ្រងអ្វីទាំងអស់។ ដូច្នេះចូរស្តាប់ចុះ។ នៅពេលបងប្អូនបោះសេចក្ដីទាំងនេះលើព្រះអម្ចាស់ តើបងប្អូនមិនកំពុងតែប្រគល់ការទាំងអស់នោះដល់ទ្រង់ទេឬអី? មិនសមហេតុផលទេ បើមិនប្រគល់ថ្វាយទ្រង់នោះ។ បងប្អូនគ្រាន់តែទទួលស្គាល់នូវអ្វីដែលទ្រង់មាននៅក្នុងការគ្រប់គ្រងរបស់ទ្រង់ទៅបានហើយ។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់យើងអំពីសេចក្ដីខ្វល់ខ្វាយហើយ មែនទេ? ទ្រង់បានមានបន្ទូលអំពីសេចក្ដីខ្វល់ខ្វាយផ្សេងៗ។ តើអ្វីដែលបងប្អូនអាចផ្លាស់ប្តូរបាន? តើបងប្អូនអាចផ្លាស់ប្តូរអ្វីមួយបានដែរឬទេ? តើបងប្អូនអាចបន្ថែមកំពស់របស់បងប្អូនបានដែរឬទេ? តើ

បងប្អូនអាចផ្លាស់ប្តូរសក់មួយសរសៃនៅលើក្បាលរបស់បងប្អូនបានដែរឬទេ? បងប្អូនមិនអាចផ្លាស់ប្តូរអ្វីបានទាំងអស់។ ដូច្នេះបងប្អូនគ្រាន់តែទទួលស្គាល់នូវអ្វីដែលទ្រង់គ្រប់គ្រងទៅ បានហើយ។ ប្រសិនបើបងប្អូនមិនថ្វាយសេចក្តីទាំងនេះដល់ទ្រង់ទេ ប្រសិនបើមិនបោះសេចក្តីទាំងនេះលើទ្រង់ទេ នោះបងប្អូនកំពុងតែនិយាយថា "**ព្រះជាម្ចាស់គ្មានអ្វីពាក់ព័ន្ធនឹងការនេះទេ។ ទ្រង់ក៏មិនមានគោលបំណងនៅក្នុងការនេះដែរ**។ ព្រះជាម្ចាស់ផ្តាច់អង្គទ្រង់ពីអ្វីដែលកំពុងតែកើតឡើងនៅលើផែនដីនេះ ដូច្នេះបានជាមានសេចក្តីខាងព្រលឹងវិញ្ញាណហើយនិងមានសេចក្តីខាងលោកិយនេះ ហើយព្រះជាម្ចាស់ធ្វើការចំពោះសេចក្តីខាងព្រលឹងវិញ្ញាណ ប៉ុន្តែនេះជាអ្វីមួយដែលខ្ញុំគួរធ្វើ ពីព្រោះការនេះបានធ្លាក់មកក្នុងកន្លែងលោកិយនេះ។ ព្រះមិនមានគោលបំណង ចំពោះអ្វីដែលខ្ញុំកំពុងតែឆ្លងកាត់ឥឡូវនេះទេ"។

ខ្ញុំមានដំណឹងសំរាប់យើងទាំងអស់គ្នានៅវេលាយប់នេះអំពីអំណាចនៃបទគម្ពីរ។ អ្វីគ្រប់យ៉ាងដែលបងប្អូនកំពុងតែឆ្លងកាត់ឥឡូវនេះ សុទ្ធតែមានគោលបំណងខាងព្រលឹងវិញ្ញាណមួយ។ វាជាសេចក្តីខាងព្រលឹងវិញ្ញាណទាំងអស់។ ព្រះជាម្ចាស់មានអំណាចគ្រប់គ្រងលើសទាំងអស់។ ទ្រង់គ្រប់គ្រងទាំងអស់។ វាសុទ្ធតែមានគោលបំណងមួយទាំងអស់។

ប្រសិនបើបងប្អូនមិនបោះសេចក្តីទាំងនេះលើទ្រង់ទេ នោះបងប្អូនកំពុងតែនិយាយថា "ទ្រង់ជ្រាបអ្វីខ្លះ? ទ្រង់អាចនឹងធ្វើចំពោះសេចក្តីខ្វល់ខ្វាយទាំងនោះបាន ប៉ុន្តែទ្រង់គ្រាន់តែមិនយកចិត្តទុក្ខដាក់ចំពោះស្ថានភាពរបស់ទូលបង្គំប៉ុណ្ណោះ។ ទ្រង់បានទុកឲ្យទូលបង្គំធ្វើការនេះ ព្រះជាម្ចាស់អើយ ពីព្រោះទ្រង់មិនខ្វល់ខ្វាយចំពោះស្ថានភាពដែលទូលបង្គំកំពុងតែឆ្លងកាត់ប៉ុណ្ណោះ"។ តើជាការគួរឲ្យចាប់អារម្មណ៍ឬទេដែលទ្រង់បានមានបន្ទូលមកយើងជាពិសេសនៅចុងបញ្ចប់នៃខ៧ដែលថា *ចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា*។ យើងអាចថ្វាយសេចក្តីនោះដល់ ពីព្រោះទ្រង់យកព្រះហឫទ័យទុកដាក់។ បងប្អូនអាចទុកចិត្តទ្រង់ថាទ្រង់នឹងដោះស្រាយសេចក្តីទុក្ខព្រួយនោះ ពីព្រោះទ្រង់ពិតជាយកព្រះហឫទ័យទុកដាក់ចំពោះបងប្អូនមែន។ ទ្រង់មិនគ្រាន់តែជ្រាបអំពីវាទេ ហើយទ្រង់មានអំណាចដើម្បីធ្វើអ្វីម្យ៉ាងចំពោះវាទៀតផង។ ទ្រង់កំពុងតែធ្វើការនៅក្នុងវាហើយ ដើម្បីបំផ្លាស់បំប្រែរាស្ត្ររបស់ទ្រង់ឲ្យបានដូចរូបអង្គនៃព្រះរាជបុត្រា។ ទ្រង់ពិតជាស្រឡាញ់ដល់បងប្អូនហើយយកព្រះហឫទ័យទុកដាក់ចំពោះបងប្អូនពិតប្រាកដមែន។ បងប្អូនអាចទុកចិត្តដល់ទ្រង់ថាទ្រង់នឹងដោះស្រាយសេចក្តីទុក្ខព្រួយនេះសំរាប់បងប្អូនបាន។

ដូច្នេះ តើសេចក្តីបន្ទាបខ្លួនមានលក្ខណៈយ៉ាងដូចម្តេច? បងប្អូនត្រូវចុះចូលនឹងអ្នកដែលមានអំណាចលើបងប្អូន។ តើបងប្អូនកំពុងតែប្រឆាំងនឹងអ្នកដែលមានអំណាចលើបងប្អូននៅត្រង់ណាមួយរបស់ជីវិតឬ? តើនោះជាអ្វីដែលធ្វើឲ្យចិត្តបងប្អូនបង្អោនចុះឬ? មានន័យថា បងប្អូនមានទស្សនៈត្រឹមត្រូវអំពីអំណាចគ្រប់គ្រង។ តើបងប្អូនកំពុងប្រឆាំងនឹងអ្នកដែលនៅក្រោមអំណាចរបស់បងប្អូនឬ? តើនោះធ្វើឲ្យចិត្តរបស់បងប្អូនបង្អោនចុះឬ? វាគឺជាការទទួលយកនូវការទំនុកបំរុងរបស់

ព្រះ។ តើបងប្អូនគិតថាជីវិតរបស់បងប្អូនទុកដូចជារឿងចៃដន្យ ឬក៏បងប្អូនដឹងថាមានគោលបំណង មួយសំរាប់អ្វីដែលបងប្អូនកំពុងតែប្រឈមមុខនៅវេលាយប់នេះ? ហើយតើបងប្អូនបានប្រមូលគ្រប់ទាំងសេចក្តីខ្វល់ខ្វាយ គ្រប់ទាំងសេចក្តីទុក្ខព្រួយ ហើយចងវាមួយដុំ រួចបោះលើភ្លៅរបស់ទ្រង់ ហើយនិយាយថា "ព្រះជាម្ចាស់អើយ វាជារបស់ទ្រង់ហើយ"។

ខ្ញុំចង់មានការប្រុងប្រយ័ត្នណាស់។ យើងមិនកំពុងតែនិយាយអំពីការមិនចេះទទួលខុសត្រូវនោះទេ មែនទេ? យើងដឹងហើយថាព្រះអម្ចាស់ធ្វើការតាមរយៈមធ្យោបាយ។ យើងកំពុងតែនិយាយអំពីអ្នកដែលយើងកំពុងទុកចិត្ត។ យើងមិនកំពុងនិយាយអំពីការភាពអសកម្មឬការមិនធ្វើអីនោះទេ។ យើងកំពុងតែនិយាយអំពីអ្នកដែលយើងទុកចិត្តថានឹងថែរក្សាយើង។

មានការបង្ហាញទី៥នៃការបន្ទាបខ្លួននៅក្នុងខទាំងនេះ។ សូមមើលនៅខ៨និង៩។ ប្រសិនបើបងប្អូនបន្ទាបខ្លួន បងប្អូននឹងចាំយាមខាងព្រលឹងវិញ្ញាណ។ មានន័យថា បងប្អូននឹងដឹងពីអ្វីម្យ៉ាង។ ហើយយើងឃើញថាការនោះតាមរយៈបទគម្ពីរ។ នៅពេលដែលបងប្អូនស្ថិតនៅក្នុងស្ថានភាពតានតឹង នៅពេលដែលបងប្អូនស្ថិតនៅក្នុងស្ថានភាពមួយដែលបងប្អូនបានទទួលសេចក្តីល្បួងឲ្យមានការភ័យខ្លាច ឲ្យមានការខ្វល់ខ្វាយ ឲ្យមានពេញដោយសេចក្តីទុក្ខព្រួយ នៅពេលនោះ សាតាំងគិតថាបងប្អូនកំពុងស្ថិតនៅក្នុងស្ថានភាពងាយគ្រោះថ្នាក់។ វាឆក់ឱកាសលើមនុស្សដែលមានពេញដោយសេចក្តីភ័យខ្លាច និងសេចក្តីខ្វល់ខ្វាយ និងសេចក្តីទុក្ខព្រួយ។ តើខ៨គ្រាន់តែត្រូវបានចាក់ចោលនៅទីនោះ ឬក៏វាធ្វើអ្វីម្យ៉ាងជាមួយប្រធានបទទាំងមូល? ខ៨។
*ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែលទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ។ ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុងលោកីយ៍នេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ។*

តើបងប្អូនឃើញទេ? នេះគឺពាក់ព័ន្ធនឹងអ្នកដែលកំពុងតែឈឺចាប់ អ្នកដែលកំពុងតែរងទុក្ខ អ្នកដែលត្រូវបានល្បួងឲ្យមានពេញទៅដោយសេចក្តីខ្វល់ខ្វាយ។ គាត់បាននិយាយថា *ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ* ។ ពីព្រោះបងប្អូនប្អូនអាចពឹងលើព្រះបន្ទូលនេះ។ មានការវាយប្រហារមួយដែលកំពុងតែមក។ មានការអញ្ជើញមួយដែលបងប្អូនតែងតែទទួលបានពីខ្មាំងសត្រូវ ហើយការអញ្ជើញនេះគឺតែងតែយ៉ាងនេះ គឺ កុំជឿព្រះអី។ កុំទុកចិត្តទ្រង់អី។ ត្រូវដោះស្រាយបញ្ហាដោយដៃរបស់អ្នកទៅ។ ចូរព្យាយាមបន្ទូការភ័យខ្លាចចេញ។ ចូរព្យាយាមបន្ទូសំពាធទាំងនេះតាមរបៀបរបស់អ្នកទៅ គឺក្នុងរបៀបមួយដែលផ្ទុយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ដោយហេតុនេះ តើបងប្អូនតតាំងនឹងអារក្សសាតាំងនៅក្នុងស្ថានភាពនេះដោយរបៀបណា? ព្រះបន្ទូលទ្រង់ប្រាប់យើងពីរបៀបតតាំងនឹងអារក្សនៅពេលឥឡូវនេះចុះ នៅខ៩មែនទេ? ចូរមានចិត្តជឿមាំ។ បងប្អូនតតាំងនឹងអារក្សនៅក្នុងស្ថានភាពទាំងនេះដោយការជឿដល់ព្រះជាម្ចាស់ ដោយការជឿដល់ព្រះបន្ទូលរបស់ទ្រង់ ដោយការទុកចិត្តទ្រង់។

តើសេចក្តីជំនឿជាអ្វី? គឺជាការទុកចិត្ត។ បងប្អូនត្រូវទុកចិត្តដល់ទ្រង់។ បងប្អូនត្រូវទុកចិត្តនូវអ្វីដែលទ្រង់មានបន្ទូល។ ខ្មាំងសត្រូវនោះមកជាមួយនៅក្នុងស្ថានភាពដ៏តានតឹងទាំងនេះ ហើយនិយាយថា "ខ្ញុំផ្តល់ផ្លូវមួយឲ្យអ្នក ដែលអ្នកមិនបាច់រង់ចាំ។ វាមិនពាក់ព័ន្ធនឹងការចុះចូលទេ។ វាមិនពាក់ព័ន្ធនឹងការពឹងដល់ព្រះជាម្ចាស់ទេ។ អ្នកត្រូវតែដោះស្រាយស្ថានភាពនេះដោយរបៀបផ្ទាល់ខ្លួនរបស់អ្នក។ ចូរបំភ្លេចរបៀបតាមព្រះគម្ពីរទៅ"។

ហើយបងប្អូនត្រូវតតាំងនឹងអារក្សដោយការឈរដោយមាំមួននៅក្នុងការទុកចិត្តចំពោះព្រះជាម្ចាស់ ដែលការនោះពាក់ព័ន្ធនឹងចំនុចទី៦នៃការបន្ទាបខ្លួន។ ចូរបងប្អូនបន្ទាបខ្លួននៅក្នុងស្ថានភាពទាំងអស់នេះដោយការកត់សម្គាល់និងការអនុវត្តនូវសេចក្តីពិតដែលបងប្អូនពាក់ព័ន្ធខាងព្រលឹងវិញ្ញាណ ពាក់ព័ន្ធខាងព្រលឹងវិញ្ញាណ។ ការនេះគឺចាប់ផ្តើមនៅក្នុងចិត្តគំនិតរបស់អ្នក ប៉ុន្តែនោះជាការពិតផងដែរនៅក្នុងជីវិតរបស់អ្នក។
សូមស្តាប់! នៅពេលដែលបងប្អូនកំពុងតែឆ្លងកាត់សេចក្តីលំបាក នៅពេលដែលបងប្អូនកំពុងឆ្លងកាត់អ្វីម្យ៉ាងដែលល្បួងបងប្អូនឲ្យមានការភ័យខ្លាច ហើយនិងសេចក្តីខ្វល់ខ្វាយ បងប្អូនត្រូវតែឈប់ហើយធ្វើការកត់សម្គាល់អ្វីម្យ៉ាង។ មិនមែនតែបងប្អូនតែនោះឯងនោះទេ។ ហើយខ្ញុំមិនមែនកំពុងតែនិយាយអំពីព្រះវត្តមានរបស់ព្រះនោះទេ។ ខ្ញុំចង់និយាយយ៉ាងដូច្នេះវិញថា បងប្អូនជាអវយវៈនៃរូបកាយព្រះគ្រីស្ទ។ បងប្អូនជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់។ សាតាំងបានបង្ហាញសេចក្តីល្បួងមួយដែលកើតញឹកញាប់និងប្រកបដោយសេចក្តីអំនួត គឺជាការដែលបងប្អូនគិតថា មានតែបងប្អូនតែឯងប៉ុណ្ណោះ ហើយ ថាបងប្អូនខុសពីគេ។ អាចនិយាយបានថា គ្មានអ្នកម្នាក់អាចយល់ពីបងប្អូនបានទេ ពីព្រោះពួកគេមិនមែនជាបងប្អូន។ អូ ងាយស្រួលណាស់ដែលអ្នកអធិប្បាយនោះនិយាយអំពីការទុកចិត្តដល់ព្រះអម្ចាស់ អំពីការបន្ទាបខ្លួន និងអំពីការផ្សេងៗទៀត ហើយខ្ញុំក៏បានឮការទាំងអស់នោះដែរ។ ប៉ុន្តែ តើអ្នកដឹងទេ? អ្នកគ្រាន់តែមិនដឹងថា ខ្ញុំកំពុងតែប្រឈមមុខនឹងអ្វីទេនៅពេលនេះប៉ុណ្ណោះ។ អ្នកគ្រាន់តែមិនដឹងពីអ្វីខ្លះដែលខ្ញុំកំពុងតែឆ្លងកាត់នៅពេលនេះប៉ុណ្ណោះ។ អ្នកគ្រាន់តែមិនដឹងថា ខ្ញុំមានអារម្មណ៍យ៉ាងណាប៉ុណ្ណោះ។

ប៉ុន្តែ យ៉ាងណាមិញ មិនត្រឹមតែបុគ្គលដែលនៅក្នុងស្ថានភាពនោះត្រូវទទួលសេចក្តីល្បួងប៉ុណ្ណោះទេ ប៉ុន្តែអ្នកដែលជុំវិញគេក៏អាចត្រូវទទួលសេចក្តីល្បួងនៅក្នុងរបៀបដូចគ្នានេះផងដែរ។ ពិតមែន

ហើយ បងប្អូនគ្រាន់តែមិនយល់ពីបុគ្គលនេះប៉ុណ្ណោះ ពីព្រោះបងប្អូនគ្រាន់តែមិនដឹងថា ពួកគេកំពុងតែឆ្លងបញ្ហាអ្វីខ្លះនោះទេ។

គួរឲ្យចាប់អារម្មណ៍ទេ? សូមស្ដាប់។ គួរឲ្យចាប់អារម្មណ៍ទេ? នៅត្រង់កណ្ដាលនៃផ្នែកនេះ យើងត្រូវបានប្រាប់ឲ្យប្រយ័ត្ននឹងសកម្មភាពរបស់អារក្សសាតាំង ហើយតស៊ូនឹងវានៅក្នុងសេចក្ដីជំនឿមាំមួនរបស់យើង ហើយយើងក៏ត្រូវបានប្រាប់អំពីការនេះផងដែរ។ នៅខ៩។

"...*ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុងលោកីយ៍នេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ*"។
មិនមែនតែបងប្អូនតែឯងនោះទេ។ បងប្អូនមិនខុសពីគេនោះទេ។ បងប្អូនមិនមែនជាបុគ្គលមុនគេដែលមានបទពិសោធន៍បែបនេះទេ។ បងប្អូនមិនមែនជាបុគ្គលមុនគេ ដែលត្រូវបានត្រាស់ហៅឲ្យបានស្មោះត្រង់ចំពោះព្រះជាម្ចាស់នោះទេ។ បងប្អូនមិនមែនជាបុគ្គលមុនគេ ដែលព្រះបានត្រាស់ហៅឲ្យស្ថិតនៅក្នុងស្ថានភាពដូចសព្វថ្ងៃនេះនោះទេ។ បងប្អូនមិនខុសពីអ្នកដទៃនោះទេ។ នោះគឺជាគំនិតដែលមានអំនួតវិញ ដែលបងប្អូនគិតថា មានតែបងប្អូនប៉ុណ្ណោះដែលទទួលសេចក្ដីល្បួងបែបនេះ។ មានតែបងប្អូនប៉ុណ្ណោះដែលទទួលការឈឺចាប់បែបនេះ។ មានតែបងប្អូនប៉ុណ្ណោះដែលបានឆ្លងកាត់ការបែបនេះ  ខណៈពេលបងប្អូនកំពុងតែឆ្លងកាត់នៅពេលបច្ចុប្បន្ននេះ។ មានតែបងប្អូនប៉ុណ្ណោះ។ នោះគឺជាគំនិតដែលមានអំនួតណាស់។

តើមិនគួរឲ្យចាប់អារម្មណ៍ទេឬអី ដែលខ៨បានប្រៀបធៀបអារក្សសាតាំងនឹងសត្វសិង្ហដែលកំពុងតែគ្រហឹមនោះ? តើបងប្អូនណាធ្លាប់មើលសត្វសឹង្ហដេញចាប់រំពាទេ? តើសត្វសឹង្ហទាំងនោះធ្វើអ្វី? តើសត្វសឹង្ហទាំងនោះព្យាយាមធ្វើអ្វី? ពួកវាចាប់សត្វដែលខ្សោយ សត្វដែលឈឺ ហើយសត្វដែលក្មេងដែលវង្វេងចេញពីហ្វូង។ មានន័យថាសត្វសឹង្ហចាប់សត្វដែលដាច់ចេញពីហ្វូង។ សត្វសឹង្ហញែកសត្វដែលជារំពាចេញពីហ្វូងហើយដេញយកតែម្ដង។
ហើយអ្នកជឿវិញ បងប្អូនកំពុងតែស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ នៅពេលដែលបងប្អូនកំពុងទទួលការឈឺចាប់ ទុក្ខព្រួយ ខ្វាយខ្វល់ក្នុងចិត្ត ហើយចាប់ផ្ដើមនៅដាច់តែឯងពីបងប្អូនខ្លួន នៅក្នុងគំនិត ឬនៅក្នុងជីវិត។ បងប្អូនចាប់ផ្ដើមផ្ដាច់ខ្លួន។ បងប្អូនចាប់ផ្ដើមនៅតែឯង។ នេះឯងជាស្ថានភាពគ្រោះថ្នាក់។ នេះវាផ្ទុយទៅនឹងការបន្ទាបខ្លួន។
 យើងទាំងអស់គ្នាសុទ្ធតែឆ្លងកាត់ការទាំងអស់នេះ។ យើងទាំងអស់គ្នាសុទ្ធតែប្រឈមមុខនឹងឧបសគ្គទាំងអស់នេះ។ ឧបសគ្គអាចនឹងមិនដូចគ្នា ប៉ុន្តែយើងទាំងអស់គ្នានឹងប្រឈមមុខនឹងការទាំងអស់នេះដូចគ្នា។

ព្រះគម្ពីរកូរិនថូស ខ្សែទី១ ជំពូក១០ ខ១៣ ចែងអំពីការនេះថា *ដ្បិតគ្មានសេចក្តីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្តីល្បួង ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន។*

តើខនេះប្រាប់បងប្អូនអ្នកជឿថា យ៉ាងដូចម្តេច? នៅពេលដែលយើងធ្លាក់ជារំពារទៅក្នុងសេចក្តីល្បួង នោះវាមិនមែនដោយព្រោះវាខ្លាំងពេកសំរាប់យើងនោះទេ។ ព្រះជាម្ចាស់មិនអនុញ្ញាតិឲ្យយើងធ្លាក់ក្នុងសេចក្តីល្បួងដោយអ្វីមួយដែលខ្លាំងពេកសំរាប់យើងរាល់គ្នាឡើយ។ តែដោយព្រោះតែយើងមិនពឹងលើទ្រង់វិញ។ យើងមិនបន្ទាបខ្លួន។ យើងដើរនៅក្នុងសេចក្តីអំនួត។ នោះជាមូលហេតុដែលយើងដួល។

ព្រះគម្ពីរសុភាសិត 18:1 ចែងយ៉ាងដូច្នេះថា *អ្នកណាដែលញែកខ្លួនចេញពីអ្នកដទៃ នោះជាអ្នករកបំពេញតែខ្លួនឯងទេ ហើយក៏មានចិត្តគ្នាន់ក្នាញ់ទាស់នឹងអស់ទាំងសេចក្តីដែលមានទំនង។*

កំពុងតែឆ្លងកាត់ការលំបាកឬ? បងប្អូនអាចនឹងនិយាយថា "ខ្ញុំគ្រាន់តែមានអារម្មណ៍ថាមិនចង់នៅព្រះវិហារ។ ខ្ញុំគ្រាន់តែមិនចង់នៅក្បែររាស្ត្ររបស់ព្រះ។ ខ្ញុំគ្រាន់តែចង់ធ្វើការនេះដោយខ្លួនឯង"។ ហើយខ្ញុំចង់និយាយទៅកាន់បងប្អូនដោយនូវអំណាចនៃព្រះគម្ពីរសុភាសិត 18:1 ថា នោះគឺជាសកម្មភាពឆោតល្ងង់ហើយ។ បងប្អូនមិននៅតែឯងទេ។ ហើយបងប្អូនត្រូវការរាស្ត្ររបស់ព្រះអម្ចាស់ ដែលការនោះនាំទីកាន់ចំនុចទី៧គឺការបន្ទាបខ្លួន។ បងប្អូនឃើញនៅក្នុងខ១០ *"រីឯព្រះដ៏មានព្រះគុណសព្វគ្រប់ ដែលទ្រង់បានហៅយើងរាល់គ្នា មកក្នុងសិរីល្អនៃទ្រង់ ដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ នោះសូមទ្រង់មេត្តាប្រោសឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ទាំងចំរើនកំឡាំង ហើយតាំងអ្នករាល់គ្នាឲ្យមាំមួនឡើង ក្នុងខណៈក្រោយដែលបានរងទុក្ខបន្តិច"*។ បងប្អូនបានបន្ទាបខ្លួននៅពេលបងប្អូនទុកចិត្តនៅក្នុងផែនការដ៏ល្អ ទន់សណ្តោសរបស់ព្រះ។ ជាសេចក្តីទន់សណ្តោស។ ទ្រង់គឺជាព្រះដែលមានគ្រប់ទាំងព្រះគុណ។ ខ្ញុំមិនសក្តិសមឲ្យទ្រង់បានថែរក្សាខ្ញុំផង។ តើខ្ញុំជាអ្នកណាដែលសមឲ្យព្រះជាម្ចាស់ មើលការខុសត្រូវចំពោះគ្រប់ផ្នែកនៃជីវិតរបស់ខ្ញុំគ្រប់ពេលវេលានោះ? តើខ្ញុំជាអ្នកណាដែលសមនឹងទទួលបានការនេះ? ប៉ុន្តែនេះជាអ្វីដែលទ្រង់ធ្វើប្រាកដមែន។ ទ្រង់ទន់សណ្តោស ហើយទ្រង់ល្អ បានជាខ្ញុំអាចមានការប្រាកដចិត្តនេះ ថាការរងទុក្ខអ្វីក៏ដោយដែលខ្ញុំឆ្លងកាត់ វាគ្រាន់តែបណ្តោះអាសន្នទេ។ ទោះប្រសិនបើវាមានរយៈពេលមួយជីវិតក៏ដោយខ១០បានចែងថា *ក្នុងខណៈក្រោយដែលបានរងទុក្ខបន្តិច*។ ប្រសិនបើវាមានរយៈពេលមួយជីវិតក៏ដោយ ក៏នៅតែបន្តិច។ ហើយព្រះជាម្ចាស់បានមានបន្ទូលប្រាប់យើងហើយសន្យានឹងយើងថា នៅចុងបញ្ចប់នៃការឈឺចាប់របស់អ្នកជឿ នោះមានអ្វីដែលកំពុងតែរង់ចាំយើង? គឺជាសិរីល្អដ៏អស់កល្បនៅក្នុងព្រះគ្រីស្ទដែលទ្រង់នឹងប្រោសឲ្យយើងបានគ្រប់លក្ខណ៍ បញ្ជាក់ឲ្យយើងដឹងច្បាស់ ទាំងចំរើនកំឡាំង ហើយតាំងយើងឲ្យមាំមួនឡើង។ បងអាននៅកណ្ឌគម្ពីរយ៉ូប ហើយបងប្អូននឹងដឹងថា អ្វីខ្លះកំពុងតែកើតឡើងនៅក្នុងជីវិតរបស់គាត់ ប៉ុន្តែកុំឲ្យបងប្អូនឈប់គិត និង

រំលឹកខ្លួនឯងឲ្យសោះថា គាត់មិនមានព្រះគម្ពីរយ៉ូបទេនៅពេលនោះ។ យ៉ូបបានរស់នៅក្នុងកណ្ឌគម្ពីរយ៉ូប។ ដូច្នេះក្នុងខណៈពេលយ៉ូបកំពុងឆ្លងកាត់ការនោះ តើគាត់ដឹងអ្វីខ្លះ? តើគាត់ដឹងពីការសន្ទនានោះនៅឯស្ថានសួគ៌ដែរឬទេ? តើគាត់ដឹងថា ព្រះយេហូវ៉ាបានមានបន្ទូលទៅសាតាំងថា "ចូរមើលយ៉ូបជាបាវបំរើរបស់អញហ្ន"? តើដឹងពីការនេះទេ?
ដូច្នេះគាត់បានដើរឆ្លងកាត់រាល់ការទុក្ខលំបាកទាំងនោះ។ ចូរមានសេចក្តីអស្ចារ្យនៅក្នុងចិត្ត ហើយនិងអ្វីដែលជាព្រះជាម្ចាស់បានបង្កើតនៅក្នុងជីវិតបុរសនេះ ក្នុងការដែលគាត់អាចនិយាយ ក្រោយពេលដែលគាត់បាត់បង់អ្វីគ្រប់យ៉ាងថា

*"ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ សូមឲ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ"។*

ទូលបង្គំទុកចិត្តទ្រង់

*"ទោះបើទ្រង់សំឡាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹងទុកចិត្តដល់ទ្រង់ដែរ ប៉ុន្តែខ្ញុំនឹងចេះតែជជែក ពីសេចក្តីសុចរិតនៃផ្លូវខ្ញុំនៅចំពោះទ្រង់"*

ហើយនៅពេលអានដល់ចុងបញ្ចប់នៃព្រះគម្ពីរយ៉ូប តើព្រះជាម្ចាស់ប្រោសដល់គាត់ដែរឬទេ? តើទ្រង់បានប្រទានរង្វាន់ដល់គាត់ដែរឬទេ? តើទ្រង់បានបញ្ជាក់ដល់គាត់ដែរទេ? តើព្រះបានតាំងគាត់ឲ្យបានមាំមួនដែរឬទេ? តើការទាំងអស់នេះសំរាប់តែលោកយ៉ូប ឬក៏សំរាប់យើងរាល់គ្នាដែរ?

ចំនុចចុងក្រោយនៅខ១១។

*"សូមឲ្យទ្រង់បានសិរីល្អ នឹងព្រះចេស្តានៅអស់កល្បជានិច្ច ជារៀងរាបតទៅ អាម៉ែន"*

អំណាចព្រះចេស្តាជារបស់ផងព្រះជាម្ចាស់ជារៀងរហូត។ នោះមានន័យថា បងប្អូនបន្ទាបខ្លួននៅពេលដែលបងប្អូនទទួលស្គាល់ ហើយបងប្អូនរីករាយនៅក្នុងអំណាចគ្រប់គ្រងរបស់ទ្រង់។ ព្រះអង្គអើយ ទ្រង់មានអំណាចព្រះចេស្តា។ ជាសិទ្ធិរបស់ទ្រង់ដែលទ្រង់ធ្វើអ្វីៗចំពោះទូលបង្គំតាមបំណងព្រះហឫទ័យទ្រង់ ដាក់ទូលបង្គំនៅកន្លែងដែលទ្រង់សព្វព្រះហឫទ័យ ទ្រង់បណ្តើរទូលបង្គំឆ្លងកាត់ស្ថានភាពនានាដែលទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំដើរ ទ្រង់បង្ហាញកិច្ចការរបស់ទ្រង់នៅក្នុងជីវិតរបស់ទូលបង្គំទៅតាមរបៀបដែលទ្រង់ជ្រើសរើស មិនថានោះជាស្ថានភាពសប្បាយរីករាយ ឬក៏ទុក្ខសោកទេ មិនថានៅក្នុងការដែលទ្រង់ប្រទានដល់ទូលបង្គំឬដកពីទូលបង្គំទេ។ ជាសិទ្ធិរបស់ទ្រង់ដែលទ្រង់ធ្វើអ្វីៗចំពោះទូលបង្គំតាមបំណងព្រះហឫទ័យទ្រង់ ពីព្រោះទ្រង់មានគ្រប់ទាំងអំណាចអស់កល្បជានិច្ច។ អាម៉ែន។
ហើយកុំឲ្យភ្លេចឲ្យសោះ។ នេះជាទំរង់មួយនៃការសរសើរដល់ទ្រង់។ តើអំណាចគ្រប់គ្រងរបស់ព្រះផ្អែមដល់បងប្អូនរាល់គ្នាទេ? តើបងប្អូនរីករាយទេ ដែលបងប្អូនដឹងថា បងប្អូនមិនមែនជាអ្នកគ្រប់គ្រងការទាំងអស់ គឺជាទ្រង់គ្រប់គ្រងគ្រប់ការទាំងអស់ យ៉ាងនោះដើម្បីឲ្យបងប្អូនបានបន្ទាបខ្លួនដោយប្រមូលសេចក្តីគ្រប់យ៉ាងដែលទាក់ទងនឹងសេចក្តីខ្វល់ខ្វាយ ដូចជា គ្រប់ទាំងការព្រួយ

បារម្ភ គ្រប់ទាំងការភ័យខ្លាច គ្រប់ទាំងការបាក់ទឹកចិត្ត គ្រប់ទាំងការព្រួយចិត្ត គ្រប់ទាំងការអស់សង្ឃឹម គ្រប់ទាំងការមិនពេញចិត្ត គ្រប់ទាំងការមិនសប្បាយរីករាយ ហើយដាក់វាមួយកញ្ចប់ហើយបោះវាទៅលើទ្រង់នៅវេលាយប់នេះបានដែរឬទេ? ដោយដឹងថា ទ្រង់នឹងថែរក្សាបងប្អូន។
ជាចុងបញ្ចប់នៅពេលយប់នេះ ខ្ញុំសូមនិយាយទៅកាន់បងប្អូនថា បងប្អូនមិនអាចធ្វើវាបានទេ ប្រសិនបើបងប្អូនមិនបានទទួលសេចក្ដីសង្គ្រោះនៅឡើយនោះ។ បងប្អូនមិនអាចទុកចិត្តអ្នកដែលបងប្អូនមិនស្គាល់បានឡើយ។ តើយប់នេះ បងប្អូនមានសមត្ថភាពក្នុងការបោះចោលគ្រប់ទាំងសេចក្ដីខ្វល់ខ្វាយចោលបានទេ? តើបងប្អូនដឹងថា ទ្រង់ពិតត្រង់ដែរឬទេ ដើម្បីឲ្យយើងអាចទុកចិត្តទ្រង់បាន? ប្រហែលមានភស្តុតាងដ៏ធំមួយគឺ ការដែលបងប្អូនមិនស្គាល់ព្រះអម្ចាស់ នោះគឺបងប្អូនមិនស្គាល់សេចក្ដីសុខសាន្តទេ ហើយក៏មិនដែលមានសេចក្ដីសុខសាន្តដែរ។ មែនទេ? ដូច្នេះសូមបងប្អូនមកឯព្រះដែលពិតត្រង់ ដើម្បីឲ្យបងប្អូនអាចទុកចិត្តទ្រង់បាន មិនត្រឹមតែក្នុងការទទួលការអត់ទោសអំពើបាបរបស់បងប្អូនប៉ុណ្ណោះទេ ប៉ុន្តែសំរាប់គ្រប់ទាំងជីវិតនៅបច្ចុប្បន្ននេះ និងជីវិតអស់កល្បទៅមុខផងដែរ? ទ្រង់ជាព្រះពិតត្រង់គួរទុកចិត្តបាន។
ចូរឲ្យរាស្ត្ររបស់ព្រះនិយាយថា "ចូរយើងអធិស្ឋាន"។ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំយើងខ្ញុំមានសេចក្ដីអំណរនៅក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់សំរាប់ទូលបង្គំយើងខ្ញុំរាល់គ្នា។ ទូលបង្គំយើងខ្ញុំមានសេចក្ដីអស្ចារ្យដោយសេចក្ដីស្រឡាញ់របស់ទ្រង់។ ទូលបង្គំយើងខ្ញុំមិនសក្តិសមនឹងសេក្ដីស្រឡាញ់នោះទេ។ ប៉ុន្តែទូលបង្គំយើងខ្ញុំសូមអរព្រះគុណទ្រង់សំរាប់សេចក្ដីស្រឡាញ់នេះ។ ហើយទូលបង្គំអធិស្ឋានសំរាប់ខ្លួនទូលបង្គំ ហើយនិងបងប្អូនរបស់ទូលបង្គំនៅពេលនេះ នៅក្នុងម៉ោងនេះ នៅក្នុងបន្ទប់នេះ ថា សូមឲ្យទូលបង្គំយើងខ្ញុំយកអ្វីៗដែលធ្វើឲ្យចិត្តរបស់ទូលបង្គំយើងខ្ញុំមានបញ្ហា និងបង្អោនចុះ ហើយឲ្យទូលបង្គំយើងខ្ញុំទទួលស្គាល់ថា អ្នកដែលកាន់សេចក្ដីទាំងនោះនៅក្នុងដៃ ដើម្បីឲ្យយើងអាចបោះគ្រប់ទាំងសេចក្ដីខ្វល់ខ្វាយលើទ្រង់ ហើយទុកសេចក្ដីទាំងនោះចោលនៅទីនោះ ព្រះអម្ចាស់អើយ ហើយទុកចិត្តទ្រង់ចំពោះសេចក្ដីទាំងអស់នេះ។ សូមព្រះវិញ្ញាណប្រើការនេះនៅក្នុងទូលបង្គំយើងខ្ញុំម្នាក់ៗ ទៅតាមរបៀបមួយដែលត្រឹមត្រូវ។ សូមរក្សាទូលបង្គំយើងខ្ញុំផងព្រះអង្គអើយ ឲ្យទូលបង្គំយើងខ្ញុំរួចពីការប្រើប្រាស់ជាប្រយោជន៍ដែលមិនត្រឹមត្រូវ។ សូមថ្វាយសិរីល្អដល់ព្រះនាមទ្រង់ក្នុងជីវិតរបស់ទូលបង្គំយើងខ្ញុំរាល់គ្នា។ ទូលបង្គំយើងខ្ញុំទូលសូមដោយនូវព្រះនាមព្រះយេស៊ូវ។ អាម៉ែន។